مدرسة اهل البيت

صلوات الله عليهم

# សាលា
# អាស្ហ់លុល-បៃត៏

## សៀវភៅសិក្សា សីលធម៌ (أَخْلَاقٌ ) ថ្នាក់ទី ៦

(អាយុ ១០-១១ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ ទង្វើដែលនាំមកនូវសុភមង្គល ........ ៤
មេរៀនទី ២ ទង្វើដែលនាំមកនូវវិនាសអន្តរាយ ........ ៧
មេរៀនទី ៣ ការយកចំណេះវិជ្ជា ........ ១០
មេរៀនទី ៤ អំណាត់ ........ ១៤
មេរៀនទី ៥ ស្មារតីប្រុងប្រយ័តឃ្មើសព្រះហឫទ័យអល់ឡោះហ្ ........ ១៦
មេរៀនទី ៦ កាលើកលែងទោស ........ ១៨
មេរៀនទី ៧ ទៅសួរសុខទុក្ខអ្នកជម្ងឺ ........ ២០
មេរៀនទី ៨ បំពេញសេចក្តីត្រូវការចាំបាច់របស់អ្នកដទៃ ........ ២១
មេរៀនទី ៩ បំណងល្អ ........ ២៣
មេរៀនទី ១០ ត៌្ហារ៉េះត៌្និងសេចក្តីស្មោកគ្រោក ........ ២៥
មេរៀនទី ១១ សកម្មការងារ ........ ២៨
មេរៀនទី ១២ ធ្វើឲ្យគេឈឺចាប់ ........ ៣០
មេរៀនទី ១៣ មាត់ប៉ប៉ាច់ប៉ប៉ោច ........ ៣២
មេរៀនទី ១៤ តមាត់ ប្រឆាំងឪពុកម្តាយ ........ ៣៣
មេរៀនទី ១៥ ការភូតភរ ........ ៣៦
មេរៀនទី ១៦ ផឹកសុរា ........ ៣៨
មេរៀនទី ១៧ ល្បែងស៊ីសង ........ ៤០
មេរៀនទី ១៨ បរិភោគជ្រូកឬរបស់ត្រូវហាម ........ ៤២
មេរៀនទី ១៩ និយាយអាក្រក់អំពីគេ ........ ៤៤
មេរៀនទី ២០ ពាក់ចិញ្ចៀនមាសនិងគ្រឿងលំអសម្រាប់បុរស ........ ៤៨
មេរៀនទី ២១ ដេកផ្កាប់មុខ ........ ៤៩

**មេរៀនទី ១**

# ទង្វើដែលនាំមកនូវសុភមង្គល

អល់ឡោះហ្ (سُبْحَانَهُ وَ تَعَالَى) មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ 2 (អាល់-បាក៏រ៉ោះត៍) អាយ៉ាស់ 277 ថា៖

إِنَّ ٱلَّذِينَ ءَامَنُواْ وَعَمِلُواْ ٱلصَّٰلِحَٰتِ وَأَقَامُواْ ٱلصَّلَوٰةَ وَءَاتَوُاْ ٱلزَّكَوٰةَ لَهُمْ أَجْرُهُمْ عِندَ رَبِّهِمْ وَلَا خَوْفٌ عَلَيْهِمْ وَلَا هُمْ يَحْزَنُونَ ﴿٢٧٧﴾

*277. បណ្ដាអ្នកមានសទ្ធា[ចំពោះអល់ឡោះហ្] ប្រព្រឹត្តអំពើល្អ ធ្វើនមស្ការ[បូជាអល់ឡោះហ្] បរិច្ចាគទាន ជនទាំងនោះមានរង្វាន់នៅឯព្រះម្ចាស់ពួកគេ ។ ពួកគេពុំជួបប្រទះការភ័យខ្លាច ពួកគេពុំមានទុក្ខសោកឡើយ ។*

មានទង្វើច្រើនដែល បើធ្វើទៀងទាត់មិនដាច់ ធ្វើឲ្យអល់ឡោះហ្ﷻទ្រង់សព្វព្រះហឫទ័យបណ្ដាអ្នកធ្វើទង្វើនោះ ។

យើងត្រូវធ្វើទង្វើល្អព្រោះវាមានផលប្រយោជន៍ដល់អ្នកដទៃ ។ ពេលយើងធ្វើទង្វើល្អ យើងធ្វើតាមបញ្ជាអល់ឡោះហ្ﷻនិងធ្វើឲ្យព្រះអង្គﷻទ្រង់សព្វព្រះហឫទ័យ ។ យើងនឹងសប្បាយចិត្តដែលបានជួយអ្នកដទៃ ។

ខាងក្រោមនេះគឺបញ្ជីរាយឈ្មោះទង្វើល្អ គឺ៖

១) ឆាប់ងើបពីដេក ធ្វើស្ឡាត់ តាហាជ្ជុដ (صلاة التهجد) និងស្ឡាត់ ហ្វាជរ៍ (صلاة الفجر គឺស្ឡាត់ ស៊ូប៊ុះហ៍ صلاة الصبح) ។

ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ 51 (អាស់-ស្ទារីយ៉ាត់) អាយ៉ាស់ 15-18 ថែង ថា៖

إِنَّ ٱلْمُتَّقِينَ فِي جَنَّٰتٍ وَعُيُونٍ ﴿١٥﴾ ءَاخِذِينَ مَآ ءَاتَىٰهُمْ رَبُّهُمْ إِنَّهُمْ كَانُواْ قَبْلَ ذَٰلِكَ مُحْسِنِينَ ﴿١٦﴾ كَانُواْ قَلِيلًا مِّنَ ٱلَّيْلِ مَا يَهْجَعُونَ ﴿١٧﴾ وَبِٱلْأَسْحَارِ هُمْ يَسْتَغْفِرُونَ ﴿١٨﴾

*15. ពិតមែន បណ្ដាអ្នកមានសទ្ធាស៊ប់ចិត្តនឹងបានឋិតនៅក្នុងសួនសួគ៌និងប្រភពទឹកផុស 16. ពួកគេបាននូវអ្វីដែលព្រះម្ចាស់ពួកគេឲ្យពួកគេ ។ ពិតមែន*

*កាលពីមុននោះពួកគេជាអ្នកប្រព្រឹត្តិល្អ ។ 17. ពួកគេធ្លាប់តែដេកតិចក្នុងពេលយប់ ។ 18. នៅពេលព្រឹក (មុនថ្ងៃរះ) ពួកគេបួងសួងសូមខមាទោស ។*

២) ពេលងើបពីដេកពេលព្រឹក ចូរអ្នកឲ្យសាឡាមឪពុកម្ដាយ សូមឪពុកម្ដាយជួយធ្វើការ ។

៣) សូត្រគួរអានពេលព្រឹកមុនទៅសាលារៀនឬមុនទៅធ្វើការ ។

ព្រះសាស្ដាមូហាំម៉ាដ់ អាល់-មុស្ដហ្វា ﷺ មានព្រះវចនៈថា៖ "បុគ្គលប្រសើរជាងគេក្នុងចំណោមអស់លោកគឺបុគ្គលដែលសិក្សាព្រះគម្ពីរគួរអាន និងបង្ហាត់ព្រះគម្ពីរគួរអានដល់អ្នកដទៃ ។"
ព្រះអង្គ ﷺ មានព្រះវចនៈដែរថា៖ "ចូរបំភ្លឺផ្ទះអស់លោកដោយសូត្រព្រះគម្ពីរគួរអាន ចូរកុំទុកឲ្យផ្ទះអស់លោកងងឹត ។ បើសូត្រព្រះគម្ពីរគួរអានជាទៀងទាត់នៅក្នុងផ្ទះ អល់ឡោះហ្ ﷻ នឹងប្រទានឲ្យនូវពរជ័យ អ្នកផ្ទះនឹងរស់នៅដោយសេចក្ដីសុខសាន្ត ប្រជានិករនៅលើមេឃនឹងឃើញផ្ទះនេះភ្លឺ ដូចមនុស្សឃើញផ្កាយភ្លឺដែរ ។"

៤) ជួយអ្នកដែលនៅក្នុងអាសន្នអន្តក្រ ។ ម្នាក់ៗទទួលបាននូវជំនួយពីអល់ឡោះហ្ ﷻ ។ អល់ឡោះហ្ ﷻ ស្រឡាញ់បណ្ដាអ្នកដែលធ្វើល្អចំពោះអ្នកដទៃ ដែលព្យាយាមជួយសង្គ្រោះគេ ។

៥) បរិច្ចាគឲ្យជនក្រីក្រ ។ អល់ឡោះហ្ ﷻ ឲ្យអ្នកមានទ្រព្យ ។ អ្នកត្រូវដឹងព្រះគុណព្រះអង្គ ﷻ ដោយបែងចែកទ្រព្យនោះជាមួយបណ្ដាអ្នកដែលខ្វះខាត ។

៦) ស្ម័គ្រចិត្តឲ្យទាន់ពេល កុំបណ្ដែតបណ្ដោយ ។ អ៊ីម៉ាំទី ៦ របស់យើង صلوات الله عليه والسلام មានវចនៈថា៖ "អ្នកណាមិនស្ម័គ្រចិត្តទាន់ពេលវេលាទេ អ្នកនោះមិនមែនគ្នាយើងទេ ។"

៧) និយាយការពិតគ្រប់កាលៈទេសៈ ។ ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "ចូរលះបង់ចោលការនិយាយកុហក ចូរនិយាយការពិតជាទម្លាប់ ។" គេធ្លាប់តែនិយាយដែរថាការនិយាយកុហកជាមេរបស់អំពើអាក្រក់គ្រប់យ៉ាង ។ ពេលអ្នកចាប់និយាយកុហក អ្នកចាប់ធ្វើទង្វើអាក្រក់ដែរ ។

៨) ទទួលភ្ញៀវ ។ ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "ពេលអល់ឡោះហ៍ﷻចង់ធ្វើល្អនៅក្នុងគ្រួសារណាមួយ ព្រះអង្គﷻចាត់បញ្ជូនអំណោយមួយទៅឲ្យគ្រួសារនោះ ។ ការពិតអំណោយនោះគឺភ្ញៀវម្នាក់ដែលនាំមកនូវកុសលផលបុណ្យពីអល់ឡោះហ៍ﷻ ហើយនាំយកបាបកម្មរបស់គ្រួសារនោះពេលលាចាកគ្រួសារនោះ ។"

មិនបានសេចក្តីថាបាបកម្មរបស់គ្រួសារនឹងរលាយបាត់អស់នោះទេ ។ បានសេចក្តីថាភ្ញៀវដែលមកឯផ្ទះគ្រួសារនោះ ជាឱកាសមួយសម្រាប់គ្រួសារនោះដើម្បីធ្វើល្អនិងទទួលគេដោយអើពើ ។ បើគ្រួសារនោះទទួលភ្ញៀវដោយរាក់ទាក់ អល់ឡោះហ៍ﷻនឹងសព្វព្រះហឫទ័យគ្រួសារនោះ ព្រះអង្គﷻនឹងលើកទោសឲ្យគ្រួសារនោះដែលបានសាងបាបកម្ម ដោយព្រះមេត្តាសន្តោស ។

៩) លាងដៃមុននិងក្រោយបរិភោគ ។

១០) នៅក្នុងអាការបរិសុទ្ធមិនដាច់ (ត៏ហ្ការ៉ោះត៍) ។ យកទឹកវូឌុអ៍ជានិច្ចមុនចូលដំណេក មុនបរិភោគ មុនសូត្រគម្ពីរអានឬមុនស្វ៊ឡាត៉ ។

១១) ចូលរួមក្នុងស្វ៊ឡាត៉យ៉ាម៉ាអុស់ (الجماعة) ។ ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថាបើអ្នកបានស្វ៊ឡាត៉រួចហើយ ពេលមកឯម៉ាស់យ៊ិដអ្នកឃើញគេកំពុងស្វ៊ឡាត៉យ៉ាម៉ាអុស់ (ស្វ៊ឡាត៉ជុំគ្នា) អ្នកគប្បីស្វ៊ឡាត៉សាថ្មីដើម្បីផ្គាប់អល់ឡោះហ៍ﷻ ។

**មេរៀនទី ២**

# ទង្វើដែលនាំមកនូវវិនាសអន្តរាយ

យើងបានអធិប្បាយអំពីទង្វើដែលនាំមកនូវសុភមង្គលខាងលើមកហើយ តែមានទង្វើអាក្រក់ដែល បើអ្នកធ្វើទង្វើអាក្រក់នោះ នឹងនាំមកឲ្យអ្នកនូវវិនាសអន្តរាយ ។

អល់ឡោះហ្ជ័ﷻចាត់ទុកទង្វើមួយចំនួនជាទង្វើអាក្រក់ ព្រោះវាធ្វើឲ្យមានវិបត្តិដល់សុខភាព ឬវាធ្វើឲ្យអ្នកដទៃឈឺចាប់ ។

ខាងក្រោមនេះគឺទង្វើអាក្រក់មួយចំនួន គឺៈ

១) ភ្លេចស្ម័ឡាត់ទាន់ពេលវេលាដោយមិនសមហេតុផល ។ ឧទាហរណ៍ បើអ្នកមើលការប្រកួតកីឡាបាល់ទាត់ក្នុងទូរទស្សន៍ ពេលដល់ម៉ោងស្ម័ឡាត់អ្នកត្រូវស្ម័ឡាត់ជាមុនសិន រួចហើយទើបមើលបន្តទៀត ។
អ៊ីមុាំទី ៦ របស់យើងصلوات الله عليه والسلامមានវចនៈថាៈ "អ្នកណាមិនស្ម័ឡាត់ទាន់ពេលវេលាទេ អ្នកនោះមិនមែនគ្នាយើងទេ ។"

២) បរិភោគពេលពេញពោះហើយ ។ នេះជាប្រការអាក្រក់ព្រោះអ្នកធ្វើឲ្យខូចទម្លាប់បរិភោគ ហេតុដូច្នេះអ្នកនឹងមានទម្ងន់ខ្លួនលើសពីធម្មតា អ្នកបង្ខំឲ្យខ្លួនអ្នកទទួលយកចំនួនលើសនេះ ។ ចាត់ទុកថាអ្នកលែងគោរពចំណីអាហារដែរ ។

៣) ងរ ។ បានសេចក្តីថាអ្នកងឿកពេលអ្នកមិនបានអ្វីដូចចិត្តចង់ ។ នេះជាប្រការអាក្រក់ព្រោះអ្នកសម្តែងអាការកកិចកកុច ធ្វើតាមតែចិត្ត ។ ពេលឪពុកម្តាយអ្នកមិនឲ្យអ្នករបស់អ្វីមួយព្រោះតែលោកដឹងថាអ្វីល្អសម្រាប់អ្នក ។

៤) ចចេស រឹងទទឹង ។ បានសេចក្តីថាអ្នកគិតថាខ្លួនអ្នកត្រូវ គេទាំងអស់គ្នា

ខុស អ្នកមិនស្តាប់គេទេ ។ អ្នកគប្បីស្តាប់គេ យកសម្តីគេមកគិតមើលសិនមុននឹងសម្រេចថាអ្វីខុស អ្វីត្រូវ ។

៥) ដេកច្រើនហួស ។ បើអ្នកដេកច្រើនពេក វាមិនល្អសម្រាប់អ្នកទេ ព្រោះកាលណាអ្នកដេកច្រើនពេក អ្នកមានអាការអស់កម្លាំងកាន់តែខ្លាំង ធ្ងន់ខ្លួនធ្វើអ្វីមិនកើត ។ បានសេចក្តីថាអ្នកទៅជាខ្ជិលច្រអូស ទម្រេតខ្លួនលើសពីធម្មតា កាន់តែទៅជាខ្ជិលច្រអូស ។ ពេលវេលាមានតម្លៃ អល់ឡោះហ៊្ ﷻ ឲ្យយើងប្រើប្រាស់ពេលវេលាដោយមានផលប្រយោជន៍ ។ ចូរកុំខ្ជះខ្ជាយពេលវេលា ។

៦) និយាយកុហក ។ និយាយកុហកជាប្រការអាក្រក់ណាស់ វាអាចក្លាយទៅជាទម្លាប់អាក្រក់បាន ។ ការនិយាយកុហកជាកូនសោចាក់បើកទ្វារជង្រុកទង្វើអាក្រក់ច្រើនទៀត ។ ព្រះសាស្តាមូហាំម៉ាដ់ ﷺ មានព្រះវចនៈថា៖ "ចូរលះបង់ចោលការនិយាយកុហក ចូរនិយាយការពិតជាទម្លាប់ ។"

៧) កោងកាចដាក់អ្នកដទៃ ។ វាជាប្រការអាក្រក់ព្រោះអ្នកធ្វើឲ្យអ្នកដទៃឈឺចិត្ត ។ អ្នកបាត់បង់សេចក្តីគោរពខ្លួនឯង មិត្តអ្នកក៏លែងគោរពអ្នកដែរបើអ្នកកោងកាចជាទម្លាប់ ។

៨) គិតថាខ្លួនគ្រាន់បើជាងអ្នកដទៃ ។ នេះជាប្រការអាក្រក់បំផុតមួយដែលគេហៅថាអភិមានៈ ។ នេះជាមូលហេតុដែលអល់ឡោះហ៊្ ﷻ មិនប្រោសប្រទានពរឲ្យស្ហៃតន ﷺ ព្រោះវា ﷺ គិតថាខ្លួនវា ﷺ ប្រសើរជាងព្រះសាស្តាអាដាំ ﷺ ។ ទោះបីខ្លួនអ្នកឆ្លាតនិងធ្វើប្រការល្អច្រើនប៉ុណ្ណាក៏ដោយ ចូរអ្នកនឹកដល់អល់ឡោះហ៊្ ﷻ និងអរព្រះគុណព្រះអង្គ ﷻ អ្នកនឹងឈប់អួតខ្លួនឯងភ្លាម ។

៩) ចំអកឲ្យគេពេលគេធ្វើខុស ។ វាជាប្រការអាក្រក់ដូចសរសើរខ្លួនឯងដែរ ។ បុគ្គលនីមួយៗជាមនុស្សដូចគ្នា ម្នាក់ៗតែងតែធ្វើខុស ។ ចំអកឬសើចឲ្យគេជាប្រការអាក្រក់ព្រោះវាធ្វើឲ្យគេឈឺចាប់ ។ ចូរគិតមើល តើអ្នកពេញចិត្តទេ

ដែលគេសើចឬចំអកឲ្យអ្នក ?

១០) នៅក្នុងអាការណាឃ្វីស (មិនស្អាត) ។ អ្នកត្រូវព្យាយាមរក្សាអាការស្អាត និងបរិសុទ្ធ ។ បានសេចក្ដីថាអ្នកត្រូវសម្អាតខ្លួនរាល់ពេលដែលអ្នកទៅបង្គន់ ត្រូវដឹងថាក្រណាត់ជូតខ្លួនអ្នកមិនណាឃ្វីស ។ បើវាទៅជាណាឃ្វីស ត្រូវសម្អាតវាដែរពេលត្រឡប់មកដល់ផ្ទះវិញភ្លាម ។ គេថាស្អាតនិងបរិសុទ្ធ (ត៏ហ្វៀរ) ជាទម្លាប់របស់ព្រះសាស្ដាទាំងឡាយ ។

**មេរៀនទី ៣**

# ការយកចំណេះវិជ្ជា

បានសេចក្ដីថាព្យាយាមសិក្សានិងយល់ដឹងអ្វីៗដែលគេននិយាយ ឬប្រាប់អ្នក ហើយយកវាមកប្រើសម្រាប់អនាគតអ្នក ។ នេះគឺទម្លាប់ល្អណាស់ ។

អ្នកមិនត្រូវចាំឲ្យគេប្រាប់អ្នកឲ្យសិក្សាទេ ។ អ្នកអាចយកចំណេះវិជ្ជាបាន ដោយមើលគេធ្វើ ដកស្រង់យកមេរៀនពីកំហុសគេនិងដោយស្រង់មយកនូវទម្លាប់ល្អរបស់គេ ។ អ្នកអាចយកចំណេះវិជ្ជាបានពីសៀវភៅដែលអ្នកអាននិងដោយសារទូរទស្សន៍ដែរ ។ ចូរអ្នកប្រុងប្រយ័តជានិច្ចពេលអ្នកកត់សម្គាល់ឃើញទម្លាប់ឬទង្វើអាក្រក់ ចូរចៀសវាងយកទម្លាប់ឬទង្វើអាក្រក់នោះមកអនុវត្តិតាម ។

ពេលគេនិយាយអ្វីជាមួយអ្នកឬប្រាប់អ្នក អ្នកត្រូវធ្វើប្រការបី គឺ៖

១. ស្ដាប់ ។

២. សិក្សា ។

៣. យល់ដឹង ។

បានសេចក្ដីថា អំណឹះតទៅ អ្នកអាចយកអ្វីដែលអ្នកសិក្សាបាននោះមកប្រើ ដើម្បីទាញយកនូវផលប្រយោជន៍សម្រាប់ខ្លួនអ្នកបាន លើសពីនោះទៀត អ្នកអាចយកវាទៅបង្ហាត់បង្រៀនគេបានដែរ ។

ប្រការសំខាន់ដែលអ្នកត្រូវដឹងអំពីចំណេះវិជ្ជាគឺ អ្នកមិនត្រូវយកចំណេះវិជ្ជានោះទៅអួតគេជាដាច់ខាត ។ ទោះបីអ្នកចេះដឹងច្រើនយ៉ាងណាក៏ដោយ ប្រាកដជានឹងមានពេលណាមួយអ្នកនឹងមិនចេះដឹងអ្វីនីមួយជាមិនខាន ។

កាលពីយូរអង្វែកមកហើយ មានស្ដេចល្បីល្បាញមួយអង្គ ។ ការល្បីល្បាញនេះមកពីស្ដេចនេះមានបុរសចំណាស់ប្រកបដោយញាណប្រាជ្ញាជាទីប្រឹក្សាម្នាក់ ។

ពេលបុរសទីប្រឹក្សាដើរតាមផ្លូវ ស្ត្រីចំណាស់ម្នាក់បានកាត់ដំណើរគាត់ សួរគាត់ថា៖ "ខ្ញុំសូមសួរលោករឿងមួយ ។" បុរសអ្នកប្រាជ្ញចំណាស់បានថា៖ "តើឲ្យខ្ញុំ

ជួយអ្វីលោកស្រី?" ស្ត្រីចំណាស់បានសួរគាត់ បុរសអ្នកប្រាជ្ញចំណាស់ដាក់ខ្លួនអង្គុយគិត។ គាត់អេះក្បាល យោកខ្លួនពីមុខទៅក្រោយ ហើយថា៖ "ខ្ញុំមិនអាចឆ្លើយលោកស្រីបានទេ ។" ស្ត្រីចំណាស់បានថា៖ "លោកជាអ្នកប្រាជ្ញរបស់ស្តេច តែលោកមិនអាចឆ្លើយសំណួរស្ត្រីចំណាស់រួច ។" បុរសចំណាស់សើចហើយថា៖ "ស្តេចជួលខ្ញុំសម្រាប់ចម្លើយដែលខ្ញុំស្គាល់ បើស្តេចជួលខ្ញុំសម្រាប់ចម្លើយដែលខ្ញុំមិនស្គាល់ ផែនដីទាំងមូលដាក់ចម្លើយដែលខ្ញុំមិនស្គាល់នោះមិនអស់ទេ ។"

រឿងនេះសឲ្យឃើញថាទោះបីគេមានប្រាជ្ញាយ៉ាងណាក៏ដោយ ប្រាកដជានឹងមានសំណួរឥតចម្លើយមួយសម្រាប់អ្នកនោះជាមិនខាន ។

ទីកន្លែងដែលយើងអាចដកស្រង់យកចំណេះវិជ្ជាបាននោះគឺផ្ទះ សាលារៀន ម៉ាស់យ៊ិដ្ធនិងសាលារៀនសាសនាអ៊ីស្លាម ។ យើងសិក្សាបាននូវអ្វីមួយថ្មីទោះបីយើងទៅទីណាក៏ដោយ ។ យើងត្រូវគោរពទីកន្លែងទាំងឡាយដែលប្រើសម្រាប់ចំណេះវិជ្ជា ដោយប្រព្រឹត្តត្រឹមត្រូវនៅទីនោះ ដោយមិនត្រឹមតែខិតខំសិក្សានៅទីនោះមួយមុខទេ តែថែមទាំងពេញចិត្តសិក្សានៅទីនោះទៀតផង ។

ឧទាហរណ៍ នៅសាលារៀន ។ យើងត្រូវគោរពលោកគ្រូអ្នកគ្រូ ព្រមទាំងខិតខំធ្វើកិច្ចការនិងស្រឡាញ់កិច្ចការដែលត្រូវធ្វើនោះ ។ ធ្វើដូច្នេះ យើងនឹងចម្រុងចម្រើនព្រមទាំងសប្បាយទៀតផង ។

សម័យព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ម៉ាស់យ៊ិដ្ធម៉ាឌីណាស្ងមិនត្រឹមតែជាកន្លែងស្ជ័ឡាត្ធទេ តែបណ្តាអ្នកមានសទ្ធាប្រជុំគ្នានៅទីនោះដើម្បីសិក្សាដែរ ។ ពេលព្រះសាស្តា ﷺ នៅ ពួកគេស្តាប់ព្រះអង្គ ﷺ សម្តែងធម៌និងទាញយកផលប្រយោជន៍ពីពាក្យពេជន៍ព្រះអង្គ ﷺ ។ ពេលព្រះអង្គ ﷺ មិននៅ បណ្តាសាវកមានជំនឿរបស់ព្រះអង្គ ﷺ ជាអ្នកបង្ហាត់បង្រៀនអ្វីៗ ដែលខ្លួនបានសិក្សាមកពីព្រះសាសនៈទូតរបស់អល់ឡោះហ៍ ﷻ ។

ថ្ងៃមួយ ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ចូលមកក្នុងម៉ាស់យ៊ិដ្ធមុនម៉ោងស្ជ័ឡាត្ធ ។ ព្រះអង្គ ﷺ ឃើញមនុស្សពីរក្រុមនៅក្នុងម៉ាស់យ៊ិដ្ធ ។ ក្នុងក្រុមមួយមានអ្នកខ្លះសូត្រព្រះគម្ពីរគួរអាន អ្នកខ្លះទៀតស្ជ័ឡាត្ធ ។ មួយក្រុមទៀតនៅម្ខាង រវល់សិក្សា ។ ពួកគាត់រៀនអាននិងរៀនសរសេរព្រះគម្ពីរគួរអាន និងពិភាក្សាគ្នាអំពីសិក្ខាបទអ៊ីស្លាម

និងអំពីការអនុវត្តិសិក្ខាទាំងនោះក្នុងជីវិតប្រចាំថ្ងៃ ។

ក្នុងពេលសម្លឹងមើលក្រុមទាំងពីរ ព្រះអង្គﷺមានព្រះវចនៈថា៖ "ពួកគាត់ទាំងពីរក្រុមរវល់នឹងកិច្ចការមានផលប្រយោជន៍ ។ តែខ្ញុំﷺជាគ្រូ ខ្ញុំﷺត្រូវចូលរួមក្នុងក្រុមដែលរវល់សិក្សា ។" ព្រះអង្គﷺក៏បានអង្គុយជាមួយក្រុមនិស្សិត ។

## លំហាត់នៅផ្ទះ

ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖

"ចូរស្វែងរកចំណេះវិជ្ជា ទោះជានៅប្រទេសចិនក៏ដោយ ។" (មើលហាឌីស្ទ ១ និងហាឌីស្ទ ២)

"ដំណេករបស់អ្នកមានចំណេះវិជ្ជាប្រសើរជាងស្វ័ឡាត់របស់អ្នកអវិជ្ជា ។" (មើលហាឌីស្ទ ៣ និងហាឌីស្ទ ៤)

ហាឌីស្ទ ១

نشانی : مصباح الشريعة , جلد۱ , صفحه۱۳
عنوان باب : الباب الخامس في العلم

معصوم : امام صادق (عليه السلام) ، پیامبر اکرم (صلى الله عليه و آله) ، اميرالمؤمنين (عليه السلام)

قَالَ اَلصَّادِقُ عَلَيْهِ السَّلاَمُ : اَلْعِلْمُ أَصْلُ كُلِّ حَالٍ سَنِيٍّ وَ مُنْتَهَى كُلِّ مَنْزِلَةٍ رَفِيعَةٍ وَ لِذَلِكَ قَالَ اَلنَّبِيُّ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ أَيْ عِلْمِ اَلتَّقْوَى وَ اَلْيَقِينِ وَ قَالَ عَلِيٌّ عَلَيْهِ السَّلاَمُ **أُطْلُبُوا اَلْعِلْمَ وَ لَوْ بِالصِّينِ** وَ هُوَ عِلْمُ مَعْرِفَةِ اَلنَّفْسِ وَ فِيهِ مَعْرِفَةُ اَلرَّبِّ عَزَّ وَ جَلَّ وَ قَالَ اَلنَّبِيُّ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ مَنْ عَرَفَ نَفْسَهُ فَقَدْ عَرَفَ رَبَّهُ ثُمَّ عَلَيْكَ مِنَ اَلْعِلْمِ بِمَا لاَ يَصِحُّ اَلْعَمَلُ إِلاَّ بِهِ وَ هُوَ اَلْإِخْلاَصُ قَالَ اَلنَّبِيُّ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ نَعُوذُ بِاللَّهِ مِنْ عِلْمٍ لاَ يَنْفَعُ وَ هُوَ اَلْعِلْمُ اَلَّذِي يُضَادُّ اَلْعَمَلَ بِالْإِخْلاَصِ وَ اِعْلَمْ أَنَّ قَلِيلَ اَلْعِلْمِ يَحْتَاجُ إِلَى كَثِيرِ اَلْعَمَلِ لِأَنَّ عِلْمَ سَاعَةٍ يُلْزِمُ صَاحِبَهُ اِسْتِعْمَالَهُ طُولَ دَهْرِهِ قَالَ عِيسَى اِبْنُ مَرْيَمَ عَلَيْهِ السَّلاَمُ رَأَيْتُ حَجَراً عَلَيْهِ مَكْتُوبٌ اِقْلِبْنِي فَقَلَبْتُهُ فَإِذَا عَلَى بَاطِنِهِ مَكْتُوبٌ مَنْ لاَ يَعْمَلُ بِمَا يَعْلَمُ مَشْئُومٌ عَلَيْهِ طَلَبُ مَا لاَ يَعْلَمُ وَ مَرْدُودٌ عَلَيْهِ مَا عَلِمَ أَوْحَى اَللَّهُ تَعَالَى إِلَى دَاوُدَ عَلَيْهِ السَّلاَمُ إِنَّ أَهْوَنَ مَا أَنَا صَانِعٌ بِعَالِمٍ غَيْرِ عَامِلٍ بِعِلْمِهِ أَشَدُّ مِنْ سَبْعِينَ عُقُوبَةً بَاطِنَةً أَنْ أُخْرِجَ مِنْ قَلْبِهِ حَلاَوَةَ ذِكْرِي وَ لَيْسَ إِلَى اَللَّهِ سُبْحَانَهُ طَرِيقٌ يُسْلَكُ إِلاَّ بِعِلْمٍ وَ اَلْعِلْمُ زَيْنُ اَلْمَرْءِ فِي اَلدُّنْيَا وَ اَلْآخِرَةِ وَ سَائِقُهُ إِلَى اَلْجَنَّةِ وَ بِهِ يَصِلُ إِلَى رِضْوَانِ اَللَّهِ تَعَالَى وَ اَلْعَالِمُ حَقّاً هُوَ

| |
|---|
| اَلَّذِي يَنْطِقُ عَنْهُ أَعْمَالُهُ اَلصَّالِحَةُ وَ أَوْرَادُهُ اَلزَّاكِيَةُ وَ صِدْقُهُ وَ تَقْوَاهُ لاَ لِسَانُهُ وَ مُنَاظَرَتُهُ وَ مُعَادَلَتُهُ وَ تَصَاوُلُهُ وَ دَعْوَاهُ وَ لَقَدْ كَانَ يَطْلُبُ هَذَا اَلْعِلْمَ فِي غَيْرِ هَذَا اَلزَّمَانِ مَنْ كَانَ فِيهِ عَقْلٌ وَ نُسُكٌ وَ حِكْمَةٌ وَ حَيَاءٌ وَ خَشْيَةٌ وَ إِنَّا نَرَى طَالِبَهُ اَلْيَوْمَ مَنْ لَيْسَ فِيهِ مِنْ ذَلِكَ شَيْءٌ وَ اَلْعَالِمُ يَحْتَاجُ إِلَى عَقْلٍ وَ رِفْقٍ وَ شَفَقَةٍ وَ نُصْحٍ وَ حِلْمٍ وَ صَبْرٍ وَ قَنَاعَةٍ وَ بَذْلٍ وَ اَلْمُتَعَلِّمُ يَحْتَاجُ إِلَى رَغْبَةٍ وَ إِرَادَةٍ وَ فَرَاغٍ وَ نُسُكٍ وَ خَشْيَةٍ وَ حِفْظٍ وَ حَزْمٍ . |
| sources:<br>https://hadith.inoor.ir/ |

## ហាឌីស្ ២

| |
|---|
| مصباح الشريعة - المنسوب للإمام الصادق (ع) - الصفحة ١٣ |
| الباب الخامس في العلم قال الصادق (ع): العلم أصل كل حال سنى ومنتهى كل منزلة رفيعة ولذلك قال النبي (ص) طلب العلم فريضة كل مسلم ومسلمة أي علم التقوى واليقين.<br>وقال علي (ع): **اطلبوا العلم ولو بالصين** فهو علم معرفة النفس ومعرفة الرب عز وجل قال النبي (ص): من عرف نفسه عرف ربه ثم عليك من العلم بما لا يصح العمل به وهو الاخلاص. |
| sources:<br>http://shiaonlinelibrary.com |

## ហាឌីស្ ៣

| |
|---|
| بحار الأنوار - العلامة المجلسي - ج ٢ - الصفحة ٢٥ |
| 82 - وقال صلى الله عليه وآله: يا علي نوم العالم أفضل من عبادة العابد، يا علي ركعتان يصليهما العالم أفضل من سبعين ركعة يصليها العابد. |
| sources:<br>http://shiaonlinelibrary.com/ |

## ហាឌីស្ ៤

| |
|---|
| شناسه حديث : ۲۲۱۴۹۵ \| نشانى : بحار الأنوار , جلد۲ , صفحه۲۵ |
| معصوم : پيامبر اكرم (صلى الله عليه و آله) |
| وَ قَالَ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ: يَا عَلِيُّ نَوْمُ اَلْعَالِمِ أَفْضَلُ مِنْ عِبَادَةِ اَلْعَابِدِ يَا عَلِيُّ رَكْعَتَانِ يُصَلِّيهِمَا اَلْعَالِمُ أَفْضَلُ مِنْ سَبْعِينَ رَكْعَةً يُصَلِّيهَا اَلْعَابِدُ. |
| sources:<br>https://hadith.inoor.ir/fa/hadith/221495/ |

ចូរសរសេរកំណត់អត្ថបទដោយប្រើពាក្យផ្ទាល់ខ្លួនរបស់អ្នក ថាតើឃ្លាទាំងពីរនេះមានន័យថាអ្វី ។

## មេរៀនទី ៤

# អំណត់

អំណត់មានន័យថាអាចរង់ចាំដោយស្ងៀមស្ងាត់បាន លុះចប់ការលំបាកនិងទុក្ខវេទនា ។ បានសេចក្ដីដែរថាអត់ឱន ។

ភាសាអារ៉ាប់សម្រាប់ហៅអំណត់គឺ ស៊ប់បារ (صَبْرٌ) ។ ព្រះសាស្ដាមូហាំម៉ាដ់យើងﷺមានព្រះវចនៈថា៖ "អំណត់ជាពាក់កណ្ដាលជំនឿ ។"

បានសេចក្ដីថាបុគ្គលណាអាចអត់ទ្រាំទុក្ខលំបាកទាំងឡាយបាន បុគ្គលនោះបានឈានមួយជំហានធំឆ្ពោះទៅកាន់ការយល់ដឹងជំនឿរបស់ខ្លួន ។

អល់ឡោះហ៊្ជﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ 2 អាយ៉ាស់ 156-157 ថា៖

ٱلَّذِينَ إِذَآ أَصَٰبَتۡهُم مُّصِيبَةٞ قَالُوٓاْ إِنَّا لِلَّهِ وَإِنَّآ إِلَيۡهِ رَٰجِعُونَ ١٥٦ أُوْلَٰٓئِكَ عَلَيۡهِمۡ صَلَوَٰتٞ مِّن رَّبِّهِمۡ وَرَحۡمَةٞۖ وَأُوْلَٰٓئِكَ هُمُ ٱلۡمُهۡتَدُونَ ١٥٧

*156. គឺបណ្ដាអ្នកដែល ពេលជួបប្រទះទុក្ខវេទនា ថ្លែងថា៖ "ពិតណាស់យើងជាកម្មសិទ្ធិរបស់អល់ឡោះហ៊្វ័ យើងវិលត្រឡប់ទៅរកព្រះអង្គវិញ ។" 157. ជនានុជនទាំងនោះគឺជនដែលបាននូវពរជ័យសិរីសួស្ដី និងព្រះមេត្តាធម៌ពីព្រះម្ចាស់ពួកគេ ហើយជនទាំងនោះជាជនដែលអនុចរតាមមាគ៌ាត្រង់ត្រូវ ។*

មានពាក្យស្លោកមួយចែងថា អំណត់ជាសីលធម៌ ។ បានសេចក្ដីថាមានអំណត់ជាគុណសម្បត្តិប្រសើរបំផុតមួយ ។ នៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ 103 (អាល់-អ៊ុស្វ៊រ៍) អាយ៉ាស់ 2-3 អល់ឡោះហ៊្វﷻមានព្រះបន្ទូលថា៖

إِنَّ ٱلۡإِنسَٰنَ لَفِي خُسۡرٍ ٢ إِلَّا ٱلَّذِينَ ءَامَنُواْ وَعَمِلُواْ ٱلصَّٰلِحَٰتِ وَتَوَاصَوۡاْ بِٱلۡحَقِّ وَتَوَاصَوۡاْ بِٱلصَّبۡرِ ٣

*2. ពិតណាស់ មនុស្សនៅក្នុងសេចក្ដីវិនាស 3. លើកលែងតែបណ្ដាអ្នកដែលមានសទ្ធា សាងអំពើល្អ ដាស់តឿន[គ្នាទៅវិញទៅមក]ឲ្យទៅកាន់សេចក្ដីពិត ដាស់តឿន[គ្នាទៅវិញទៅមក]ឲ្យអត់ធ្មត់[នៅលើមាគ៌ាអល់ឡោះហ៊្វ័] ។*

សឲ្យឃើញច្បាស់ថាក្នុងសាសនាអ៊ីស្លាម ធ្វើល្អដើម្បីខ្លួនឯងមិនគ្រប់គ្រាន់សម្រាប់ផ្គាប់អល់ឡោះហ៊្ ﷻ ទេ ។ អ្នកត្រូវបង្ហាត់គេឲ្យចេះដឹងអ្វីដែលអ្នកជឿនោះដែរ ហើយអ្នកត្រូវមានអំណត់ ។

## មេរៀនទី ៥

# ស្មារតីប្រុងប្រយ័តកុំឃ្មើសព្រះហឫទ័យអល់ឡោះហ៊្ ﷿ (តាក់វ៉ា تقوى)

គេច្រើនតែបកប្រែពាក្យ តាក់វ៉ា ថា "ខ្លាចក្រែងអល់ឡោះហ៊្﷿" ។ នេះពុំមែនសម្រាយត្រឹមត្រូវទេ ព្រោះវាអាចមានន័យថាជឿអល់ឡោះហ៊្﷿នោះធ្វើឲ្យសត្វលោកព្រះអង្គ﷿ភ័យខ្លាច ហើយនេះមិនមែនការពិតទេ ។

នៅក្នុងសាសនាអ៊ីស្លាម ទ្រឹស្តី "ខ្លាចក្រែងអល់ឡោះហ៊្﷿" មិនមែនភ័យខ្លាចអល់ឡោះហ៊្﷿នោះទេ តែខ្មាស បារម្ភនិងសោកសៅព្រោះតែបានប្រព្រឹត្តប្រការនីមួយដែលធ្វើឲ្យព្រះអង្គ﷿ឃ្មើសព្រះហឫទ័យ (គឺធ្វើឲ្យអល់ឡោះហ៊្﷿ទាស់ចិត្ត) ។

មិនមានសម្រាយចំសម្រាប់ទ្រឹស្តីនេះទេ គេហៅថាតាក់វ៉ាៗដូច្នេះ ។

យើងទាំងអស់គ្នាដឹងថាករណីយកិច្ចសំខាន់បំផុតរបស់មុស្លីមនោះគឺ ជឿអល់ឡោះហ៊្﷿និងចុះចូលក្នុងឱវាទព្រះអង្គ﷿ទាំងស្រុង ។ ព្រះឆន្ទៈព្រះអង្គ﷿ជាព្រះបញ្ជាលើយើង ។ យើងដឹងដែរថាបើយើងធ្វើឲ្យព្រះអង្គ﷿ទាស់ចិត្ត ថ្ងៃជំនុំជម្រះយើងនឹងត្រូវសាកសួរអំពីទង្វើយើង ។

សំខាន់បំផុតគឺ បើយើងធ្វើអ្វីមួយដោយចេតនាឬដោយអចេតនា យើងត្រូវ "ដឹងខ្លួន" អំពីអ្វីដែលយើងបានធ្វើនិងអំពីលទ្ធផលចុងក្រោយរបស់ទង្វើនោះ ហើយយើងសូមឲ្យអល់ឡោះហ៊្﷿លើកទោសឲ្យយើង ។ ពិបាកឈានដល់អាការ "ដឹងខ្លួន" នេះណាស់ ។ យើង ដែលជាមនុស្សសាមញ្ញ មិនអាចទៅដល់អាការនេះជាដាច់ខាតបើគ្មានជំនួយនិងការណែនាំពីអល់ឡោះហ៊្﷿នោះ ។ អល់ឡោះហ៊្﷿មានព្រះបន្ទូលនៅក្នុងស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ ថា៖ "ចូរធ្វើសក្ការៈអញ ដើម្បីអញនឹងការពារពួកអ្នកពីស៊ៃតន" ។ សឲ្យឃើញច្បាស់ថាទ្រឹស្តីសក្ការៈមានន័យថាចុះចូលនិងស្រឡាញ់ស៊ប់ចិត្តចំពោះអល់ឡោះហ៊្﷿ នេះជាប្រការសំខាន់ណាស់ដើម្បីធ្វើឲ្យស៊ៃតន لعن الله ឃ្លាតឆ្ងាយពីយើង ។

នៅក្នុងស៊ូរ៉ោះតួ៍ អាន់-នូរ អល់ឡោះហ្ ﷻ មានព្រះបន្ទូលថាព្រះអង្គ ﷻ នឹងដឹកនាំបណ្ដាអ្នកណាដែលចង់ឲ្យគេដឹកនាំនៅលើមាគ៌ាត្រូវ ។ សឲ្យឃើញពិតៗថាមានតែតាមរយៈការស្រឡាញ់និងការធ្វើសក្ការៈចំពោះអល់ឡោះហ្ ﷻ ទេ ដែលគេនឹងដឹកនាំយើងទៅកាន់ "មាគ៌ាត្រូវ" លុះដល់ឋានសួគ៌នោះ ។

តើនេះមិនមែនគោលបំណងចម្បងរបស់យើងទេក្នុងជីវិត ?

## មេរៀនទី ៦

# ការលើកលែងទោស

លើកលែងទោសមានន័យថា "មិនខឹងអ្នកដទៃ" ពោលគឺ អភ័យទោសឲ្យគេដែលបានធ្វើខុសមកលើខ្លួនអ្នក ។

ការលើកលែងទោសជាទង្វើមួយដែលល្អណាស់ សឲ្យឃើញថាអ្នកមានចិត្តទូលំទូលាយ ។

អល់ឡោះហ៍ﷻមានព្រះបន្ទូលប្រាប់យើងនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះតុ៍ 64 (អាត់-តាក៏ប៊ូន) អាយ៉ាស់ 14 ថា៖

يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُوٓاْ إِنَّ مِنۡ أَزۡوَٰجِكُمۡ وَأَوۡلَٰدِكُمۡ عَدُوّٗا لَّكُمۡ فَٱحۡذَرُوهُمۡۚ وَإِن تَعۡفُواْ وَتَصۡفَحُواْ وَتَغۡفِرُواْ فَإِنَّ ٱللَّهَ غَفُورٞ رَّحِيمٌ ١٤

*14. អ្នកមានសទ្ធាទាំងឡាយអើយ! ពិតណាស់នៅក្នុងចំណោមបណ្តាភរិយានិងកូនៗរបស់ពួកអ្នកមានសត្រូវរបស់ពួកអ្នក ។ ដូច្នេះចូរពួកអ្នកប្រយ័តពួកគេ ។ បើពួកអ្នកអត់ឱន បំភ្លេចនិងលើកលែងទោសពៃរ៍[ពួកគេ] ពិតណាស់ អល់ឡោះហ៍ទ្រង់លើកលែងទោស ព្រះអង្គមានព្រះមេត្តាករុណាប្រណី ។*

បានសេចក្តីថា បើអ្នកមានចិត្តល្អគ្រាន់បើអាចលើកលែងទោសឲ្យបុគ្គលដែលធ្វើខុសមកលើខ្លួនអ្នកបាន អល់ឡោះហ៍ﷻ ដែលប្រសើរដាច់គេនោះ នឹងលើកលែងទោសឲ្យអ្នកដែរ ។ ព្រះសាស្តាអ៊ីសាﷺមានព្រះវចនៈថាអ្នកត្រូវធ្វើចំពោះអ្នកដទៃនូវអំពើដែលអ្នកចង់ឲ្យអ្នកដទៃធ្វើចំពោះខ្លួនអ្នកដែរ ។ បានសេចក្តីថាបើអ្នកចង់ឲ្យគេកុំយកកំហុសអ្នក អ្នកត្រូវតែកុំយកកំហុសគេមុន ។

អ៊ីម៉ាំអាលីصلوات الله عليه والسلامមានវចនៈថា៖ "បុគ្គលណាដែលបានទទួលការលើកទោសពីអល់ឡោះហ៍ﷻ បុគ្គលនោះដូចទារកដែលទើបនឹងកើតពីពោះម្តាយ ។"

ពេលកូនខ្ចីទើបនឹងកើត វាបរិសុទ្ធ គ្មានបាប ។ ទាំងអស់គ្នាស្រឡាញ់វាព្រោះវាមិនបានធ្វើកំហុសសោះ វាមិនធ្វើបាបលើអ្នកណាមួយសោះ ។

ពេលអល់ឡោះហ៍ﷻលើកលែងទោសឲ្យអ្នកណាមួយ អ្នកនោះទៅជាបរិសុទ្ធ ។ អល់ឡោះហ៍ﷻធ្វើឲ្យចិត្តនិងវិញ្ញាណអ្នកនោះទៅជាបរិសុទ្ធដូចចិត្តនិង

វិញ្ញាណរបស់កូនខ្ចីដែលទើបនឹងកើតពីពោះម្ដាយ ។

អ៊ីម៉ាំ មូសា អាល់-កាស៊ីមصلوات الله عليه والسلام មានវចនៈថា៖ "ទង្វើរបស់អស់លោកប្រៀបបាននឹងរឿងផ្ទាល់ខ្លួនរវាងអស់លោកនិងអល់ឡោះហ្ទ័عز وجل ។ បើអស់លោកសូមទោសដែលបានធ្វើទង្វើនីមួយក្នុងអំឡុងពេល ៧ ម៉ោង វាជាប្រការល្អសម្រាប់អស់លោក ។"

បើអ្នកប្រយ័តទង្វើរបស់អ្នកហាក់ដូចជាអល់ឡោះហ្ទ័عز وجلរាប់ទង្វើនោះ ពេលអ្នកធ្វើខុសភ្លាម អ្នកសូមទោសអល់ឡោះហ្ទ័عز وجلភ្លាមមុនចុងថ្ងៃ (គឺឲ្យបានមុនថ្ងៃបន្ទាប់) ។

ដូច្នេះ ពេលអ្នកចូលដំណេក អ្នកនឹងដឹងថាអ្នកបានទូទាត់ទង្វើទាំងអស់របស់អ្នកជាមួយអល់ឡោះហ្ទ័عز وجلស្រេចបាច់ហើយ ។ អ្នកនឹងអាចដេកបានស្រួលដោយឥតកង្វល់ ។

## លំហាត់នៅផ្ទះ

ចូរសរសេរកំណត់អត្ថបទដោយប្រើពាក្យផ្ទាល់ខ្លួនរបស់អ្នក ថាតើហ៊ាឌីស្ទពីរខាងលើនេះមានន័យថាអ្វី ។

អ្នកអាចឲ្យឪពុកម្ដាយជួយធ្វើលំហាត់នេះបាន ។

## មេរៀនទី ៧

# ទៅសួរសុខទុក្ខអ្នកជម្ងឺ

ពេលអ្នកទៅលេងអ្នកជម្ងឺ អ្នកធ្វើឲ្យគាត់រីករាយ ។ ហេតុអ្វីគាត់រីករាយ ?

មូលហេតុដែលធ្វើឲ្យគាត់រីករាយ គឺគាត់ដឹងថាអ្នកបារម្ភគាត់ ។

បានសេចក្តីថាអ្នកជម្ងឺ ប្រុសឬស្រី ដឹងថាអ្នកមិនភ្លេចគាត់ទេ ថាមានគេបារម្ភអំពីសុខភាពគាត់ ។

ព្រះសាស្តាមូហាំម៉ាដ្ឋយើងﷺធ្លាប់តែទៅម៉ាស់ឃ្ជិដ្ឋរាល់ថ្ងៃ មានស្ត្រីចំណាស់ម្នាក់ចោលសំរាមមកលើក្បាលព្រះអង្គﷺ រាល់លើកដែលព្រះអង្គﷺដើរកាត់តាមនោះ ។ គាត់ធ្វើបែបនេះរាល់ថ្ងៃ ព្រះសាស្តាយើងﷺមិនថាអ្វីទេព្រោះព្រះអង្គﷺគោរពចាស់ទុំ ។

ថ្ងៃមួយ អស់រយៈពេលយូរក្រោយមក ស្ត្រីចំណាស់មិនចោលអ្វីមកលើខ្លួនព្រះសាស្តាﷺទេ ។ ព្រះសាស្តាﷺបារម្ភគាត់ ក៏បានទៅមើលស្ត្រីចំណាស់នោះ ។ ទៅដល់ផ្ទះគាត់ ព្រះអង្គﷺហៅគាត់ សួរសុខទុក្ខគាត់ សួរគាត់ថាតើព្រះអង្គﷺអាចជួយអ្វីគាត់បានទេ ដើម្បីនឹងឲ្យគាត់បានស្រួលខ្លួនឡើងវិញ ។ ស្ត្រីចំណាស់ភ្ញាក់ផ្អើល គាត់សប្បាយចិត្តដែលមានគេបារម្ភគាត់ មកមើលគាត់ ។ គាត់ក៏បានសូមទោសព្រះសាស្តាមូហាំម៉ាដ្ឋﷺ ហើយក៏បានទៅជាស្ត្រីមុស្លីមស៊ប់ចិត្ត ។

នេះគឺភ័ស្តុតាងបញ្ជាក់ថាទៅសួរសុខទុក្ខអ្នកជម្ងឺជាប្រការសំខាន់មួយ អ្នកពិតជាធ្វើឲ្យគាត់សប្បាយចិត្ត គាត់នឹងមានសុខភាពប្រសើរឡើង គាត់នឹងចងចាំអ្នកជានិច្ច នឹងស្រឡាញ់អ្នកខ្លាំងឡើង ។

តើអ្នកដែលឈឺ ចូលមន្ទីរពេទ្យទេ ? បើធ្លាប់ តើអ្នកមានអារម្មណ៍ដូចម្តេចពេលគេមកលេងអ្នក ? តើអ្នកមានអារម្មណ៍ដូចម្តេចពេលគេយករបស់ហូបនិងអំណោយមកឲ្យអ្នក ? ហេតុអ្វីអ្នកមានអារម្មណ៍ដូច្នេះ ?

**មេរៀនទី ៨**

# បំពេញសេចក្តីត្រូវការចាំបាច់របស់អ្នកដទៃ

សេចក្តីត្រូវការកើតឡើងកាលណាអ្នកណាម្នាក់ចង់បានអ្វីមួយ ឬត្រូវតែមានអ្វីមួយដែលអាចធ្វើឲ្យអ្នកនោះរស់បាន ។ ទឹកនិងអាហារជាសេចក្តីត្រូវការសំខាន់បំផុតសម្រាប់សត្វលោកមានជីវិតគ្រប់រូប ។

ពេលយើងមានអ្វីដែលគេពុំមាន យើងគប្បីបែងចែក បើអាចធ្វើបាន ដើម្បីនឹងបំពេញសេចក្តីត្រូវការចាំបាច់របស់អ្នកដទៃដែរ ។

សេចក្តីត្រូវការចាំបាច់មានច្រើនប្រភេទ ។ បើបុគ្គលជាជនក្រីក្រយើងអាចជួយគេបានដោយឲ្យប្រាក់ ។

មានអ្នកខ្លះមិនមានសមត្ថភាពធ្វើការនីមួយបាន ។ បុគ្គលនោះមិនអាចធ្វើបានដោយងាយស្រួលដូចយើងទេ ។ គាត់មិនត្រូវការប្រាក់ទេព្រោះគាត់មិនក្រទេ តែគាត់ត្រូវការមិត្តភាពនិងការរាប់អាន ។ យើងមិនត្រូវសើចឲ្យបុគ្គលទាំងនេះទេ មិនត្រូវចំអកឲ្យគាត់ទេ តែយើងត្រូវទៅរកគាត់ ចងមិត្តភាពជាមួយគាត់ ធ្វើឲ្យគាត់ដឹងខ្លួនថាគាត់ដូចយើងដែរ មិនខុសពីយើងទេ ។

មានបុគ្គលខ្លះដែរដែលមិនទុកចិត្តខ្លួនឯង ដែលច្រើនតែទាស់ខុសនិងភ្លាំងភ្លាត់ ។ ចូរកុំចំអកឲ្យគាត់ យើងគប្បីជួយគាត់ កម្លានិងលើកទឹកចិត្តគាត់ ។ ពេលអ្នកណាមួយទាស់ខុស ចូរកុំស្រែកស្តីបន្ទោស តែចូរធ្វើបង្ហាញគាត់ដើម្បីកែខ្លួនឲ្យល្អឡើង ។ អ្វីដែលគាត់ត្រូវការគឺមិត្តស្មោះដើម្បីជួយជ្រោមជ្រែងគាត់ ។

មានអ្នកខ្លះដែលពុំមានសំណាងមានឪពុកម្តាយ មានគ្រួសារឬមិត្តជាអាណាព្យាបាលឬជាអ្នកជួយឲ្យបានយល់ដឹងអ៊ីស្លាម ។ ពួកគេមានឪពុកម្តាយតែឪពុកម្តាយនោះមិនបង្ហាត់ពួកគេឲ្យចេះដឹងអ៊ីស្លាមត្រឹមត្រូវទេ ។

តើយើងត្រូវធ្វើអ្វីបើបុគ្គលទាំងនេះឲ្យយើងធ្វើទង្វើអាក្រក់ ដូចជាស្តាប់ភ្លេងឬមើលកុនមិនគប្បី ឬបរិភោគអាហារដែលច្បាប់ហាមជាដើម ?

យើងត្រូវពន្យល់ពួកគេដោយសមរម្យថាហេតុអ្វីយើងមិនត្រូវធ្វើបែបនេះ និងណែនាំពួកគេទៅរកមាគ៌ាអ៊ីស្លាម ដូច្នេះពួកគេនឹងអាចរស់នៅបានដោយសេចក្តី

សុខសប្បាយព្រមទាំងធ្វើឲ្យអល់ឡោះហ៍ عزوجل ទ្រង់សព្វព្រះហឫទ័យផង ។

និយាយសរុប យើងអាចជួយបុគ្គលរាល់គ្នាបានដោយវិធីផ្សេងៗ ។ ពេលយើងឃើញចំណុចខ្សោយនិងបញ្ហារបស់អ្នកដទៃ យើងត្រូវប្រុងប្រយ័តកុំឲ្យជួបប្រទះបញ្ហាតែមួយនិងកុំឲ្យមានចំណុចខ្សោយដែរ ។ បើយើងមានចំណុចខ្សោយ យើងត្រូវព្យាយាមកែខ្លួនឲ្យប្រសើរជាងមុន ។

**មេរៀនទី ៩**

# បំណងល្អ

ពេលអ្នកមានបំណងមួយ បានសេចក្តីថាអ្នកដឹងថាអ្នកនឹងធ្វើទង្វើអ្វី ហេតុអ្វីអ្នកធ្វើទង្វើនោះ ។

ក្នុងសាសនាអ៊ីស្លាម បំណងមានសារៈសំខាន់នៅក្នុងករណីយកិច្ចទាំងអស់របស់យើង ព្រោះបើគ្មានបំណងច្បាស់លាស់ ទង្វើភាគច្រើនរបស់យើងទៅជាមោឃៈ អសារបង់ ។

ចូរស្មានមើលបុគ្គលម្នាក់កំពុងស៊ូឡាត់ គាត់អាចស៊ូឡាត់បានល្អណាស់តែគេអាចមិនទទួលយកស៊ូឡាត់គាត់ទេ ។ នេះមកពីពេលយើងស៊ូឡាត់ យើងស៊ូឡាត់ដោយមានមូលហេតុផ្សេងៗ ដូចជា៖

ក. ដើម្បីផ្គាប់អល់ឡោះហ៍ﷻ ។

ខ. ដើម្បីសម្ញែងគេថាយើងខ្លាចក្រែងអល់ឡោះហ៍ﷻ ។

គ. បើយើងមិនស៊ូឡាត់ទេ ឪពុកម្តាយយើងនឹងស្តីឲ្យយើង ។

ពិតណាស់ ទាល់តែយើងមានគោលបំណងទីមួយ (ក) ទើបគេទទួលយកស៊ូឡាត់យើង ។

ភាសាអារ៉ាប់ហៅគោលបំណងថា "នៀត (نِيَّة)" ។ ទង្វើនីមួយៗត្រូវដឹកនាំមុខដោយនៀតល្អមួយ ។ ហាឌីស្ហព្រះសាស្តាមូហ៊ាំម៉ាដ់យើងﷺថ្លែងថា៖ "ទង្វើយើងត្រូវនាំមុខដោយគោលបំណងយើង ។"

បានសេចក្តីថា បាបឬទង្វើល្អដែលយើងធ្វើស្ថិតនៅលើមូលហេតុដែលជម្រុញយើងឲ្យធ្វើ ។ ឧទាហរណ៍ អ្នកបរិច្ចាគប្រាក់ច្រើនជាទាននៅចំពោះមុខមហាជន ។ ធ្វើបែបនេះមិនខុសទេ ដោយផ្អែកទៅលើនៀតរបស់អ្នក ។ បើអ្នកបរិច្ចាគប្រាក់ដើម្បីឲ្យគេឃើញថាអ្នកជាអ្នកមាន ថាអ្នកមានចិត្តសប្បុរសនោះ ទង្វើរបស់អ្នកមិនមានតម្លៃទេសម្រាប់អល់ឡោះហ៍ﷻ ។ តែបើអ្នកបរិច្ចាគប្រាក់ក្នុងគោលបំណងធ្វើឲ្យបណ្តាអ្នកដែលឃើញអ្នកធ្វើនោះយកតម្រាប់តាមអ្នក ហើយធ្វើដូច

អ្នកដែរ អល់ឡោះហ៊្ញ ទ្រង់សព្វព្រះហប្ញទ័យទង្វើរបស់អ្នក ។

ទោះបីយើងធ្វើអ្វីក៏ដោយ យើងត្រូវមាននៀតត្រឹមត្រូវ (គឺមានគោលបំណងល្អ) ។ យើងមិនបាច់ប្រាប់ឲ្យគេដឹងទេថាយើងធ្វើទង្វើនីមួយដើម្បីអ្វី បើយើងដឹងច្បាស់នៅក្នុងចិត្តថាហេតុអ្វីយើងធ្វើទង្វើនោះ ។

អ្វីក៏ដោយដែលយើងធ្វើ យើងត្រូវមាននៀតតែមួយគត់នៅក្នុងចិត្តជានិច្ច គឺនៀតថាយើងធ្វើអ្វីៗដើម្បីផ្គាប់អល់ឡោះហ៊្ញ ជានិច្ច ។

## មេរៀនទី ១០

# ត៍ហ្ការ៉ោះត៍និងសេចក្តីស្មោកគ្រោក

ត៍ហ្ការ៉ោះត៍ (طهارة) មានន័យថាជ្រះស្អាតប្រាសចាកសេចក្តីស្មោកគ្រោក ។ ត៍ហ្កៀរ (បរិសុទ្ធ) មានន័យថាជ្រះស្អាតសម្រាប់សាសនាអ៊ីស្លាម ។ ពាក្យទាំងពីរនេះខុសគ្នា ។

បើអ្នកស្លៀកពាក់ថ្មី ចូរងូតទឹកហើយលាបទឹកអប់ អ្នកនឹងស្អាត ។ ឧទាហរណ៍ អ្នកចូលបង្គន់ អ្នកមិនប្រើទឹកលាងជម្រះទេ ។ គេចាត់ទុកថាអ្នកស្អាត តែអ្នកទៅជាណាយ៉ីស ។ ពេលយើងចូលបង្គន់ យើងត្រូវតែលាងជម្រះ ៣ ដង ដើម្បីទៅជាត៍ហ្កៀរ ។ ប្រើក្រដាសបង្គន់សម្រាប់ជម្រះនោះមិនល្អទេ ព្រោះវាជូតជ្រះតែមិនធ្វើឲ្យត៍ហ្កៀរទេ ។

ព្យាយាមរក្សាខ្លួនឲ្យត៍ហ្កៀរ (ឬ បរិសុទ្ធ) ជាទម្លាប់ល្អ ។ អ៊ីម៉ាំទី ៨ របស់យើង صلوات الله عليه والسلام មានវចនៈថា៖ "បរិសុទ្ធនិងជ្រះស្អាតជាប៉ែកមួយនៃទម្លាប់របស់បណ្តាព្រះសាស្តា ។"

ព្រះសាស្តាមូហ៊ាំម៉ាដ់ صلى الله عليه وآله وسلم មានព្រះវចនៈដែរថា៖ "សេចក្តីជ្រះស្អាតនិងសេចក្តីបរិសុទ្ធជាប៉ែកមួយរបស់ជំនឿ ។"

ផ្ទុយពីត៍ហ្កៀរគឺណាយ៉ីស ផ្ទុយពីស្អាតគឺស្មោកគ្រោក ។ គេត្រូវចៀសវាងណាយ៉ីសនិងស្មោកគ្រោកជានិច្ច ។ អ៊ីស្លាមបង្ហាត់យើងឲ្យចេះរក្សាខ្លួនឲ្យត៍ហ្កៀរនិងស្អាតគួបគ្នាជានិច្ច ដូចខាងក្រោមនេះ គឺ៖

**វូឌុអ៊ុ** (اَلْوُضُوء)

អ៊ីស្លាមឲ្យយើងលាងសម្អាតខ្លួនមុនរាល់ស្វ៍ឡាត់ ។ គេហៅស្នានពិធីទាំងនេះថា វូឌុអ៊ុ ។ មូលហេតុដែលយើងធ្វើវូឌុអ៊ុ គឺ៖

ក) យើងទៅជាស្អាត ។

ខ) វាធ្វើឲ្យយើងស្រឡះស្រឡំចិត្ត និងធ្វើឲ្យយើងមានសមត្ថភាពធ្វើឲ្យចិត្តមូលបាននិងមានគំនិតថ្លា ។

## គូស៊ូល (الْغُسْل)

មានន័យថាសម្អាតខ្លួនជាមួយនៀតថាជម្រះបន្សុទ្ធចិត្ត ។ មានច្រើនមូលហេតុដែលតម្រូវឲ្យធ្វើស្ពានពិធីគូស៊ូល ។ ឧទាហរណ៍ ពេលអ្នកបានប៉ះពាល់សាកសព អ្នកត្រូវតែងូតទឹកគូស៊ូលជាមុនសិនទើបអាចស្ម័ឡាត្ដ៏បាន ។

## ងូតទឹកសម្អាតខ្លួនរាល់ថ្ងៃ

អ៊ីស្លាមជាសាសនាដែលមិនត្រឹមតែ ណែនាំអ្នកឲ្យរក្សាចិត្តឲ្យបរិសុទ្ធតែប៉ុណ្ណោះទេ ថែមទាំងណែនាំអ្នកឲ្យរក្សាខ្លួនប្រាណឲ្យបរិសុទ្ធដែរ ។ អ្នកត្រូវតែងូតទឹកឲ្យទៀងទាត់ដើម្បីរក្សាខ្លួនប្រាណឲ្យជ្រះស្អាតចាកមន្ទិល ។

## លាងសម្អាតមុខនិងដុសធ្មេញ

ពេលព្រឹក ពេលអ្នកងើបពីដំណេក អ្នកត្រូវលាងសម្អាតមុខអ្នកនិងដុសធ្មេញ ។ ធ្វើដូច្នេះអ្នកនឹងមានអារម្មណ៍ភ្លឺថ្លា ថែមទាំងធ្វើឲ្យជ្រះអស់សំណល់ស្មោកគ្រោកដែលជិតជាប់កាលពីយប់មក ។

ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺមានព្រះវចនៈថា៖ "យកល្អអស់លោកគប្បីដុសធ្មេញ ។ ការពិត ដុសធ្មេញធ្វើឲ្យមាត់អស់លោកបរិសុទ្ធ ធ្វើឲ្យអល់ឡោះហ៊្ ﷻទ្រង់សព្វព្រះហឫទ័យ ថែមទាំងធ្វើឲ្យភ្នែកអស់លោកមើលឃើញច្បាស់ឡើង ។ ម្យ៉ាងទៀត ទេវតាស្អប់ក្លិនមាត់មិនស្អាតក្រោយពីបរិភោគរួច ។"

## ស្លៀកពាក់ស្អាតបាត

មុស្លីមមិនត្រូវស្លៀកពាក់សំលៀកបំពាក់ស្មោកគ្រោកជាដាច់ខាត ។ មិនបានសេចក្ដីថាអ្នកត្រូវស្លៀកពាក់ សំលៀកបំពាក់ស្អាតឆើតឆាយនិងថ្លៃបំផុតនោះទេ ។ បានសេចក្ដីថាបើអ្នកមានតែសំលៀកបំពាក់តែមួយបន្លាស់ អ្នកត្រូវតែរក្សាវាឲ្យស្អាតចាកមន្ទិលជានិច្ច ។

ពេលអ្នកស្លៀកពាក់ អ្នកត្រូវស្លៀកពាក់ដើម្បីខ្លួនឯង មិនត្រូវស្លៀកពាក់ដើម្បីសម្ដែងគេទេ ។

## កាត់ក្រចក

អ្នកត្រូវកាត់ក្រចកឲ្យទៀងទាត់ ព្រោះវាឆាប់វែងហើយឆាប់ប្រឡាក់ប្រឡូសទៅជាស្មោកគ្រោក ។

បើអ្នកទុកឲ្យក្រចកអ្នកដុះវែងពេក វត្ថុស្មោកគ្រោកអាចជាប់នៅក្រោមក្រចកនោះ ។ ពេលអ្នកបរិភោគ វត្ថុស្មោកគ្រោកនឹងធ្លាក់ទៅលើចំណី ចូលទៅក្នុងពោះអ្នក ។ វាជាប្រការអាក្រក់សម្រាប់សុខភាពអ្នក អាចធ្វើឲ្យមានជម្ងឺច្រើនមុខ ។

## សិតសក់

រាល់គ្នាត្រូវសិតសក់ វែកសក់ឲ្យសមរម្យជានិច្ច ។ អ្នកមិនត្រូវបណ្តោយឲ្យសក់អ្នកកខ្វក់និងមិនរៀបរយជាដាច់ខាត ។

ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា បើអ្នកមិនអាចថែរក្សាសក់ខ្លួនឯងឲ្យសមរម្យបានទេ យកល្អឲ្យកោរក្បាល ។

សឲ្យឃើញថាថែរក្សាសក់ក្បាលជាប្រការសំខាន់ ។ មិនបានសេចក្តីថាអ្នករវល់តែរៀបចំសក់ក្បាលអ្នកគ្រប់សរសៃឲ្យមានរបៀបនោះទេ ។ អ្នកត្រូវព្យាយាមរក្សាសក់ក្បាលអ្នកឲ្យវាជ្រះស្អាតនិងមានរបៀប ។

ប្រការសំខាន់ដែលត្រូវចងចាំសេចក្តីអធិប្បាយខាងលើនេះ គឺអ៊ីស្លាមបង្ហាត់បង្រៀនយើងឲ្យចេះថែរក្សាខ្លួនប្រាណឲ្យជ្រះស្អាតពីសេចក្តីស្មោកគ្រោក ព្រោះខ្លួនប្រាណជ្រះស្អាតនាំឲ្យមានសុខភាពល្អ ។ បើយើងមិនថែរក្សាខ្លួនប្រាណទេ យើងនឹងមានជម្ងឺច្រើនប្រភេទ ច្រើនបែប ។ បើអ្នករក្សាខ្លួនប្រាណបានជ្រះស្អាត អ្នកនឹងមានអារម្មណ៍ល្អនិងត្រជាក់ចិត្ត ។

ដូចគេបានបង្ហាត់បង្រៀនយើងឲ្យចេះថែរក្សាចិត្តឲ្យបរិសុទ្ធ (ត៉ូហ្វៀរ) នោះដែរ គេឲ្យយើងចេះដឹងថាចិត្តឬវិញ្ញាណជ្រះស្អាតធ្វើឲ្យចិត្តឬវិញ្ញាណនោះឥតវិកល ។

**មេរៀនទី ១១**

# សកម្មការងារ

ព្យាយាមធ្វើការងារបានសេចក្ដីថា ប្រមូលអារម្មណ៍និងខិតខំធ្វើកិច្ចការនីមួយទាល់តែបានសម្រេច ។

អ្នកធ្លាប់ឮគេនិយាយជាញឹកញយថា "បើគ្រាដំបូងពុំបានសម្រេច ចូរព្យាយាមម្ដងហើយ ម្ដងទៀត" ។

អ៊ីស្លាមគាំទ្រសេចក្ដីសម្មការងារ ។ បើអ្នកព្យាយាមប្រកបកិច្ចការនីមួយយ៉ាងសកម្មមិនគិតពីការនឿយហត់ អ្នកប្រាកដជានឹងបានសម្រេចជាមិនខាន ។

គេតែងតែថា "មិនបានសម្រេចដោយបានសាកល្បងប្រសើរជាងមិនបានសាកល្បងទាល់តែសោះ ។"

អ្នកមានសទ្ធាត្រូវតែសកម្មការងារលើសអ្នកដទៃជានិច្ច ។ ព្រោះមនុស្សភាគច្រើនប្រកបកិច្ចការដើម្បីធ្វើឲ្យជីវិតរស់នៅក្នុងលោកនេះចម្រើន ពោលគឺចំណីអាហារ ផ្ទះសម្បែង ប្រាក់ គ្រួសារ ។ល ។

ទោះជាយ៉ាងណាក៏ដោយ អ្នកមានសទ្ធាត្រូវប្រព្រឹត្តដើម្បីជីវិតលោកនេះនិងជីវិតលោកមុខ ។ ការប្រព្រឹត្តដែលប្រសើរបំផុតដើម្បីលោកមុខនោះ គឺប្រព្រឹត្តខ្លួនត្រឹមត្រូវក្នុងជីវិតលោកនេះ បំពេញស្វ៏ឡាត្ទ៏ទាន់ពេលវេលា និងជួយបណ្ដាអ្នកដែលនៅក្នុងអាសន្នអន្ទក្រ ។

ថ្ងៃមួយ អ៊ីម៉ាំមួយអង្គរបស់យើង(صلوات الله عليه والسلام)សកម្មកិច្ចការក្នុងចម្ការ ។ ព្រះអង្គ(صلوات الله عليه والسلام)កាប់គាស់ដីកណ្ដាលថ្ងៃក្ដៅស្ទើរខ្លោច មិនអើពើអំពីការនឿយហត់ទេ ។ បុរសម្នាក់ដើរកាត់តាមនោះ ឃើញអ៊ីម៉ាំយើង(صلوات الله عليه والسلام)បែកញើសសស្រាក់ កំពុងកាប់គាស់ដី ។ គាត់បានប្រាប់អ៊ីម៉ាំ(صلوات الله عليه والسلام)ថា៖ "ព្រះរាជបុត្រ(صلوات الله عليه والسلام)ព្រះសាស្ដា(صلى الله عليه وآله وسلم)អឺយ ព្រះអង្គ(صلوات الله عليه والسلام)មិនខ្មាសគេទេ ?" អ៊ីម៉ាំងើបមុខ សួរថា៖ "ហេតុអ្វី ខ្ញុំ(صلوات الله عليه والسلام)ធ្វើអ្វីខុស ?" បុរសតបថា៖ "ព្រះអង្គ(صلوات الله عليه والسلام)ធ្វើការធ្ងន់ដើម្បីលោកនេះ ភ្លេចព្រះ(عز وجل)ព្រះអង្គ(صلوات الله عليه والسلام) ។" អ៊ីម៉ាំ(صلوات الله عليه والسلام)តបថា៖ "ប្រកបកិច្ចការហ្ហាឡាល់ជាការធ្វើសក្ការៈមួយបែបចំពោះអល់ឡោះហ្វ៏(عز وجل) ។"

នេះសឲ្យឃើញថា អ៊ីស្លាមជាសាសនាដែលនាំយើងទៅរកជីវិតរស់នៅស្មើភាព ។ ច្បាប់អ៊ីស្លាមមិនត្រឹមតែពាក់ព័ន្ធនឹងការសូត្រព្រះគម្ពីរគួរអាននិងស៊ូទ្បាត់ទេ តែពាក់ព័ន្ធនឹងការងារនិងរបៀបរស់នៅដែរ ។

## មេរៀនទី ១២

# ធ្វើឲ្យគេឈឺចាប់

មនុស្សរាល់គ្នាសុទ្ធតែមានមនោសញ្ចេតនា មានសតិអារម្មណ៍ ។ ពុំមានអ្វីអាក្រក់ជាងការរងរបួសនៅក្នុងចិត្តទេ ព្រោះវាពិបាកជាសះស្បើយណាស់ ។

បើអ្នកគ្រវែងដុំថ្មទៅលើអ្នកណាមួយ វានឹងធ្វើអ្នកនោះរបួស ។ ដុំថ្មកាន់តែធំ ធ្វើអ្នកនោះកាន់តែឈឺខ្លាំង ។ បើប៉ះជើង អ្នកនោះអាចដើរមិនរួច ឬបើប៉ះភ្នែក អ្នកនោះអាចមើលមិនឃើញ ។

អណ្តាតមនុស្សរលាស់ចេញមកនូវសម្តី ជួនកាលសម្តីនោះធ្វើឲ្យរបួសធ្ងន់ជាងដុំថ្ម ។ ដុំថ្មរបួសខ្លួន តែសម្តីរបួសចិត្ត ។

សុភាសិតថា៖ "អណ្តាតមុតជាងដាវ ។"

បានសេចក្តីថា ជួនកាល ពេលអ្នកនិយាយស្តី វាអាចធ្វើឲ្យមានរបួសធ្ងន់លើសផ្លែដាវដ៏មុតទៅទៀត ។

បើអ្នកដាក់ឈ្មោះក្រៅឲ្យគេ ឬជេរប្រមាថគេ ឬចំអកឲ្យគេ អ្នកអាចធ្វើឲ្យគេរបួសចិត្ត (ឈឺចិត្ត) ។ វាធ្វើឲ្យគេអាក់អន់ស្រពន់ចិត្ត គេនឹងមានអារម្មណ៍ថាពុំមានតម្លៃសម្រាប់អ្នកដទៃ ។

ចូរយកពេលគិតបន្តិច ។ ចូរស្មានថាអ្នកជាអ្នកនោះវិញ ។ អ្នកចូលចិត្តទេ ដែលគេហៅឈ្មោះអ្នកប្លែកៗ ធ្វើឲ្យអ្នកពិបាករស់នៅ ។ អ្នកចូលចិត្តទេដែលគេសើចពេលអ្នកដួល ឬគេនិយាយកំប្លែងមកលើខ្លួនអ្នក ។ អ្នកចូលចិត្តទេដែលគេចំអកឲ្យគ្រួសារអ្នក ឬចំអកឲ្យពណ៌សម្បុរអ្នក ឬចំអកឲ្យអាការខ្លួនអ្នក ។ **ទេ អ្នកមិនចូលកចិត្តទេ**!

បើអ្នកមិនចូលចិត្តទេ ហេតុអ្វីអ្នកប្រព្រឹត្តអំពើនេះលើអ្នកដទៃ ?

អល់ឡោះហ៊្ស៊ូបានបង្កើតយើងទាំងអស់គ្នាមកស្មើគ្នា ។ អ្នកខ្លះស្ទាត់ជំនាញខាងប្រការនីមួយ អ្នកឯទៀតប៉ិនប្រសប់ខាងប្រការឯទៀត ។

អំណឺះតទៅ ពេលអ្នកនិយាយដាក់គេ ទោះបីជាការលេងសើចក៏ដោយ វា

អាចមិនមែនការលេងសើចសម្រាប់គេ ។ ចូរអ្នកគិតសិនមុននិយាយ ថាសម្ដីអ្នកអាចធ្វើឲ្យមានឥទ្ធិពលអាក្រក់លើគេ ។

**មេរៀនទី ១៣**

# មាត់ប៉ប៉ាច់ប៉ប៉ោច

និយាយប៉ប៉ាច់ប៉ប៉ោចមានន័យថានិយាយច្រើនហួសអំពីសព្វគ្រប់ អំពីប្រការអសារៈ ឥតប្រយោជន៍ មិនឈប់ ។

យើងនឹងឃើញថា គេមិនសូវយកចិត្តទុកដាក់នឹងបុគ្គលនិយាយច្រើនទេ ។ ដូច្នេះ គេមិនគោរពបុគ្គលនោះទេ ។ បុគ្គលនោះពុំមានមិត្តជិតស្និទ្ធទេ មនុស្សអាចនឹងចៀសវាងបុគ្គលនោះ ។ ជាទូទៅ គេចាត់ទុកបុគ្គលនោះដូចកូនក្មេង ។

ពេលគេនិយាយច្រើន គេអាចបើកអាថ៌កំបាំងឲ្យអ្នកផងដឹងដោយមិនដឹងខ្លួន ។ ដូច្នេះហើយបានជាអ៊ីមុាំអាលីصلوات الله عليه والسلامមានវចនៈថា៖ "ចិត្តរបស់បុគ្គលភ្លីភ្លើនៅលើអណ្ដាត ។"

សឲ្យឃើញថាអាថ៌កំបាំងរបស់បុគ្គលភ្លីភ្លើត្រូវបើកឲ្យគេដឹង ពេលបុគ្គលភ្លីភ្លើនោះនិយាយ ។ ផ្ទុយពីនេះ បុគ្គលចេះដឹងនិយាយតែអ្វីដែលគួរនិយាយ ដូច្នេះហើយបានជាអ៊ីមុាំអាលីصلوات الله عليه والسلامមានវចនៈដែរថា៖ "អណ្ដាតរបស់បុគ្គលចេះដឹងនៅក្នុងចិត្ត ។"

មនុស្សច្រើនតែប្រើការនិយាយប៉ប៉ាច់ប៉ប៉ោច ។ អ្នកខ្លះ ពេលជួបជុំគ្នា ច្រើនតែនិយាយអំពីរឿងឥតខ្លឹមសារ និយាយអំពីអ្នកដទៃ និយាយអំពីខ្លួនឯងបានធ្វើខ្លះបានទៅណាខ្លះ ។ សម្ដីទាំងអស់នេះក្លាយទៅជាការនិយាយបង្ខូចគេ (غِيبَة) និងជម្លោះ (فِتْنَة) ។ អ្នកត្រូវតែចៀសវាងការជួបជុំឬក្រុមមនុស្សបែបនេះជានិច្ច ព្រោះអ្នកមិនទទួលបាននូវផលប្រយោជន៍សោះ ។ នៅក្នុងការជួបជុំឬក្នុងក្រុមមនុស្សបែបនេះច្រើនតែមានអ្នកណាម្នាក់ត្រូវគេបង្ខូចឈ្មោះ បង្ខូចកិត្តិយស ។

ព្រះសាស្ដាអ៊ីសាعَلَيْهِ السَّلاَمមានព្រះវចនៈប្រាប់យើងថា ត្រូវប្រើពាក្យសម្ដីដូចមាស ។ តើអ្នកបាចមាសទៅលើគេដូចដីខ្សាច់ទេ ? ប្រាកដជាទេ ពាក្យសម្ដីថ្លៃណាស់ មិនអាចចាត់ទុកដូចល្អងធូលីបានទេ ដើម្បីនឹងយកវាទៅបាចចោលនោះ ។

## មេរៀនទី ១៤

# តមាត់ ប្រឆាំងឪពុកម្តាយ

នេះជាបញ្ហាជួបប្រទះញឹកញយ នៅក្នុងពិភពលោកប៉ែកខាងលិចសព្វថ្ងៃនេះ ។ វាបណ្តាលឲ្យមានហិង្សាច្រើន មានកិរិយាមារយាទអគប្បីនិងការបង្កឲ្យមានការខូចខាត នៅក្នុងយុវៈភាពសម័យនេះ ។

អល់ឡោះហ្ជ៏មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ 17 (អាល់-អ៊ិសរ៉អ៊ុ ឬ បានី អ៊ីសរ៉អ៊ីល) អាយ៉ាត់ 23 ថា៖

۞وَقَضَىٰ رَبُّكَ أَلَّا تَعْبُدُوٓا۟ إِلَّآ إِيَّاهُ وَبِٱلْوَٰلِدَيْنِ إِحْسَـٰنًا ۚ إِمَّا يَبْلُغَنَّ عِندَكَ ٱلْكِبَرَ أَحَدُهُمَآ أَوْ كِلَاهُمَا فَلَا تَقُل لَّهُمَآ أُفٍّ وَلَا تَنْهَرْهُمَا وَقُل لَّهُمَا قَوْلًا كَرِيمًا ﴿٢٣﴾

*23. ព្រះម្ចាស់អ្នកបានដាក់បញ្ញាថាឲ្យពួកអ្នក (មនុស្សទាំងឡាយ) គោរពបូជាតែព្រះអង្គមួយគត់ ឲ្យពួកអ្នកប្រព្រឹត្តល្អចំពោះឪពុកម្តាយពួកអ្នក ។ បើអ្នកណាម្នាក់ ឬអ្នកទាំងពីរមានវ័យជរានៅជាមួយអ្នក ចូរអ្នកកុំនិយាយស្តីថា "ថ្វីយ! (ជាពាក្យពោលចេញមក សម្តែងឲ្យឃើញថាមានការធុញទ្រាន់ រំខាន ឬ ស្អប់)" ឡើយ ចូរអ្នកកុំគំហកដាក់អ្នកទាំងពីរឡើយ ចូរអ្នកមានវាចារកពួកគេដោយប្រើសំដីល្អប្រពៃ [ដោយគោរព] ។*

សឲ្យឃើញថាស្តាប់បង្គាប់ឪពុកម្តាយជាប្រការសំខាន់ណាស់ មិនស្តាប់បង្គាប់ឪពុកម្តាយជាប្រការហ៊ារ៉ាំ ។

សំណួរ - ហេតុអ្វីយើងត្រូវស្តាប់បង្គាប់ឪពុកម្តាយ ?

ចម្លើយ - ឪពុកម្តាយយើងចាស់ជាងយើង លោកទទួលបាននូវបទពិសោធន៍ច្រើនជាងយើង ។ លោកបានលះបង់ច្រើនដើម្បីយើង ។ លោកយកចិត្តទុកដាក់នឹងយើងខ្លាំងណាស់ ពេលលោកប្រាប់យើងអ្វីមួយព្រោះតែចង់ឲ្យយើងល្អ ។

អល់ឡោះហ្ជ៏បានប្រាប់ព្រះសាស្តាមួយអង្គរបស់ព្រះអង្គ៏ថា៖ "អញ៏សូម

ស្បថចំពោះព្រះកិត្តិយសអញﷻថា អ្នកណាមួយមិនស្តាប់បង្គាប់ឪពុកម្តាយ ទោះបីអ្នកនោះមករកអញﷻដោយនាំមកនូវទង្វើដូចព្រះសាស្តាដែរក៏ដោយ ក៏អញﷻមិនព្រមទទួលអ្នកនោះជាដាច់ខាត ។"

បើយើងមិនស្តាប់បង្គាប់ឪពុកម្តាយទេ យើងមិនស្តាប់បង្គាប់អល់ឡោះហ្ ﷻទេ ដូច្នេះយើងនឹងមិនស្តាប់អ្នកណាឡើយ ។ បានសេចក្តីថាយើងនឹងមិនគោរពច្បាប់ទេ យើងនឹងធ្វើផ្តេសផ្តាស តាមតែចិត្ត ។ នេះគឺអ្វីដែលកំពុងកើតឡើងនៅក្នុងពិភពលោកប៉ែកខាងលិចសព្វថ្ងៃនេះ ។ ក្មេងៗធ្វើអ្វីតាមតែចិត្ត ក្លាយទៅច្រឡោះបោះ និងហិង្សា ឃោរឃៅ ។ ក្មេងៗសម័យឥឡូវនេះនៅតែតមាត់ ប្រឆាំងឪពុកម្តាយ មិនដែលស្គាល់អាកប្បកិរិយាមារយាទគប្បីទេ អាស្រ័យហេតុនេះ ពួកគេនឹងក្លាយទៅជាឪពុកម្តាយមិនល្អក្នុងអនាគត ពេលពួកគេនឹងមានកូន ។

នេះសឲ្យឃើញថាបើយើងមិនស្តាប់បង្គាប់ឪពុកម្តាយយើងទេ យើងបំផ្លិចបំផ្លាញជីវិតខ្លួនឯងព្រោះយើងនឹងចិញ្ចឹមកូនយើង ដោយបង្ហាត់កូនៗយើងឲ្យចេះល្មើសបង្គាប់ ។

អាយ៉ាទុលឡោះហ៍ ឃូមៃលី មានប្រសាសន៍ថា៖ "មើលមុខឪពុកឬម្តាយខ្លួនដោយសេចក្តីគោរព ប្រៀបបាននឹងមើលព្រះមហាគ្រឹះកាក់បាស្ហ៍ គឺបានរង្វាន់ស្មើគ្នា ។"

អ៊ីមុាំអាលី صلوات الله عليه والسلام មានវចនៈថា៖ "ចូរអស់លោកគោរពឪពុកអស់លោក កូនៗរបស់អស់លោកនឹងគោរពអស់លោកដែរ ។"

## លំហាត់នៅផ្ទះ

ចូរពន្យល់ តើហាឌីស្ទពីរខាងក្រោមនេះមានន័យថាអ្វី ។

១. "ចូរអស់លោកគោរពឪពុកអស់លោក កូនៗរបស់អស់លោកនឹងគោរព

អស់លោកដែរ ។"

២. "អញ ﷻ សូមស្បថចំពោះព្រះកិត្តិយសអញ ﷻ ថា អ្នកណាមួយមិនស្ដាប់បង្គាប់ឪពុកម្ដាយ ទោះបីអ្នកនោះមករកអញ ﷻ ដោយនាំមកនូវទង្វើដូចព្រះសាស្ដាដែរក៏ដោយ ក៏អញ ﷻ មិនព្រមទទួលយកទង្វើនោះជាដាច់ខាត ។"

## មេរៀនទី ១៥

# ការភូតភរ

ភូតភរបានសេចក្ដីថានិយាយអ្វីដែលអ្នកដឹងច្បាស់ថាវាមិនពិត ដោយចេតនា ។

យើងទាំងអស់គ្នាដឹងថានិយាយកុហកជាបាបធំមួយ ។ អាក្រក់បំផុតគឺ ជួនកាលយើងនិយាយកុហកទាំងមិនដឹងខ្លួន ។

អ៊ីមុាំទី ៦ របស់យើង صلوات الله عليه والسلام មានវចនៈថាពិបាកលុបលាងបាបតូចច្រើនជាងលុបលាងបាបធំតែមួយ ។ ចូរនឹកដល់រឿងបុរសពីរនាក់ដែលបានមករកអ៊ីមុាំ صلوات الله عليه والسلام ដើម្បីលុបលាងបាបដែលខ្លួនបានធ្វើ ។

ព្រះសាស្ដាមូហ៊ាំម៉ាដ់ صلى الله عليه وآله وسلم មានព្រះវចនៈថា៖

"ចូរលះបង់ចោលការនិយាយកុហក ចូរនិយាយការពិតជាទម្លាប់ ។"

"បើអ្នកណាមួយធ្លាប់តែនិយាយកុហក អ្នកនោះជាមនុស្សធ្វើពុតបើអ្នកនោះមិនលះបង់ចោលទម្លាប់នេះទេ ។"

កុហក ភូតភរ ជាប្រការហាមឃាត់ ព្រោះអ្នកធ្វើឲ្យគេខូចចិត្ត ។ មានមូលហេតុច្រើនដែលជម្រុញឲ្យនិយាយមុសា ដូចជា៖

ក. ដើម្បីដោះសាយកខ្លួនរួច ។

ខ. ដើម្បីបោកប្រាស់គេយកអ្វីមួយ ។

គ. ដើម្បីធ្វើឲ្យគេរងការលំបាក ។

អ្នកឃើញហើយថាមូលហេតុខាងលើនេះជាមូលហេតុមិនត្រឹមត្រូវទេ ។ បើអ្នកបានប្រព្រឹត្តខុស អ្នកត្រូវប្រឈមនឹងប្រការខុសនោះ មិនត្រូវភូតភរដោះសាយកខ្លួនរួចទេ ពីព្រោះធ្វើបែបនេះបានសេចក្ដីថាអ្នកខ្វះស្មារតីទទួលខុសត្រូវ ។

ព្រះគម្ពីរគួរអាន (ស៊ូរ៉ោះតុ៏ អាល់-បាក៏រ៉ោះតុ៏ អាយ៉ាស់ 42) បង្ហាត់យើងកុំឲ្យនិយាយភូតភរថា៖

وَلَا تَلۡبِسُواْ ٱلۡحَقَّ بِٱلۡبَٰطِلِ وَتَكۡتُمُواْ ٱلۡحَقَّ وَأَنتُمۡ تَعۡلَمُونَ ٤٢

*42. ចូរពួកអ្នកកុំលាយឡំសេចក្តីពិតជាមួយសេចក្តីមុសាឡើយ ចូរពួកអ្នកកុំបិទបាំងសេចក្តីពិតឡើយ ខណៈដែលពួកអ្នកដឹង ។* (2:42)

ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈដែរថា៖ "ចូរអស់លោកប្រយ័តទំនាក់ទំនងជាមួយមនុស្សភូតភរ ព្រោះវាដូចមរិចិកា (គឺរូបបំភាន់ភ្នែក) ដែលទាញពីឆ្ងាយមកជិត ទាញពីជិតទៅឆ្ងាយ ។"

បើអ្នកនិយាយមុសាជាទម្លាប់ អ្នកនឹងនិយាយភូតភរជាញឹកញយទាំងមិនដឹងខ្លួន ។ អ្នកនឹងនិយាយកុហកគ្រួសារអ្នក មិត្តអ្នកនិងអ្នកផងឥតរើសមុខ ។ ថ្ងៃណាមួយគេនឹងចាប់កំហុសអ្នកបានព្រោះអ្នកទាល់ប្រាជ្ញាលែងឆ្លើយដោះសាខ្លួនរួច អ្នកមិនអាចគេចរួចទេ ។

បើអ្នកនិយាយមុសាជាទម្លាប់ អ្នកអាចធ្វើទង្វើអាក្រក់ផ្សេងៗទៀតបានដែលអាក្រក់លើសនិយាយកុហកទៅទៀត ។ បាបរមែងតែនាំមកនូវបាបមួយទៀត ។

## មេរៀនទី ១៦

# ផឹកសុរា

ពេលយើងនិយាយអំពីសុរា បានសេចក្តីថា ស្រាទំពាំងបាយជូរ ប៊ីយ៉ែរ ទឹកស្រវឹងផ្អែមម្យ៉ាង ស្រាផ្លែប៉ោម (ឬទឹកប៉ោមមានជាតិស្រវឹង) ។



យើងទាំងអស់គ្នាដឹងថា សុរាជាវត្ថុហ៊្សារ៉ាំ ។

តើយើងដឹងទេថា ហេតុអ្វីគេហាមយើងផឹកសុរា ?

យើងដឹង ពីព្រោះសុរាមិនល្អសម្រាប់យើងទេ ។ យើងដឹងថាអល់ឡោះហ៊្វ عز وجل ទ្រង់មហាមេត្តាប្រណីជាទីបំផុត ព្រះអង្គ عز وجل មិនហាមយើងប្រការណាមួយទេ វៀរលែងតែប្រការនោះមានគ្រោះថ្នាក់សម្រាប់យើង ។

បានជាសុរាជាគ្រោះថ្នាក់សម្រាប់យើងនោះ ពីព្រោះវាធ្វើឲ្យយើងឃ្លាតឆ្ងាយពីអាការធម្មតារបស់ខ្លួនយើង ។

យើងបានដឹងអំពីណាហ្វ៍ស៍ (نَفْس) រួចពីមុនមកហើយ និងអំពីការណ៍ដែលវាដឹកនាំយើងទៅរកបាប ។ ពេលបុគ្គលផឹកសុរា សូម្បីតែបន្តិចបន្តួចក៏ដោយ វាជះឥទ្ធិពលភ្លាមៗទៅលើសតិអារម្មណ៍និងខ្លួនប្រាណ ។

សុរាកាត់បន្ថយសមត្ថភាពប្រមូលផ្តុំអារម្មណ៍ឲ្យមូល ដូច្នេះយើងមិនអាចគ្រប់គ្រងណាហ្វ៍ស៍យើងបានល្អប្រសើរទេ ។ ហេតុដូច្នេះ យើងងាយធ្វើប្រការបាប ។ អាការខ្វះអារម្មណ៍មូលនេះជះឥទ្ធិពលអាក្រក់ ទៅលើខួរក្បាលនិងសមត្ថភាពវិនិច្ឆ័យរបស់យើងដែរ ។ យើងអាចក្រេវក្រោធនិងធ្វើអំពើដែលធ្វើឲ្យយើងមានវិប្បដិសារៈនៅពេលក្រោយបាន ។ នេះមកពីខួរក្បាលអ្នកគ្រប់គ្រងខ្លួនអ្នកមិនបានល្អ ។

សុរាជះឥទ្ធិពលអាក្រក់ទៅលើខ្លួនប្រាណដោយបំផ្លិចបំផ្លាញថ្លើម និងធ្វើឲ្យស្មារតីប្រតិកម្មយើងយឺតយ៉ាវ ។ ដូច្នេះ វាអាចជាមូលហេតុបង្កគ្រោះថ្នាក់បាន ជាពិសេសពេលបើកបរ ។ សុរាមិនល្អសម្រាប់សង្គមដែរជាទូទៅ ។ យើងនឹង

អធិប្បាយលំអិតអំពីចំណុចនេះក្នុងមេរៀនក្រោយ ។

ចូរចងចាំថា អល់ឡោះហ្ទ៍عَزَّ وَجَلَّហាមយើងតែប្រការណាដែលមិនល្អសម្រាប់យើងទេ ដែលអាចធ្វើឲ្យខូចសតិអារម្មណ៍ អាចធ្វើឲ្យខូចស្មារតី អាចធ្វើឲ្យខូចខ្លួនប្រាណឬវិញ្ញាណ ។

**មេរៀនទី ១៧**

# ល្បែងស៊ីសង

លេងល្បែងស៊ីសងជាប្រការ**ហារ៉ាំ** ។ បាបមួយនេះធ្ងន់ស្មើផឹកសុរាដែរ អល់ឡោះហ៊្ញបានដាក់បាបទាំងពីរនេះបន្តបន្ទាប់គ្នា នៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ 5 (អាល់-ម៉ាអ៊ីដាស់) អាយ៉ាស់ 90 ថា៖

يَـٰٓأَيُّهَا ٱلَّذِينَ ءَامَنُوٓا۟ إِنَّمَا ٱلْخَمْرُ وَٱلْمَيْسِرُ وَٱلْأَنصَابُ وَٱلْأَزْلَـٰمُ رِجْسٌ مِّنْ عَمَلِ ٱلشَّيْطَـٰنِ فَٱجْتَنِبُوهُ لَعَلَّكُمْ تُفْلِحُونَ ﴿٩٠﴾

*90. បណ្ដាអ្នកមានសទ្ធាអើយ សុរានិងល្បែងស៊ីសង កន្លែងបូជា (គឺសិលាតម្កើងសម្រាប់បូជារូបបដិមា) និង[ការបែងចែកអាស្រ័យ]គ្រាប់ព្រួញជាភាពស្មោកគ្រោកស្នាដៃរបស់ស្ហៃតនូ ។ ដូច្នេះចូរពួកអ្នកចៀសឆ្ងាយពីវា ដើម្បីពួកអ្នកនឹងមានជ័យជំនះ ។*

ព្រះអង្គ‌ﷻមានព្រះបន្ទូលនៅក្នុងស៊ូរ៉ោះត៍ 2 (អាល់-បាក៏រ៉ោះត៍) អាយ៉ាស់ 219 ថា៖

۞ يَسْـَٔلُونَكَ عَنِ ٱلْخَمْرِ وَٱلْمَيْسِرِ ۖ قُلْ فِيهِمَآ إِثْمٌ كَبِيرٌ وَمَنَـٰفِعُ لِلنَّاسِ وَإِثْمُهُمَآ أَكْبَرُ مِن نَّفْعِهِمَا ۗ وَيَسْـَٔلُونَكَ مَاذَا يُنفِقُونَ قُلِ ٱلْعَفْوَ ۗ كَذَٰلِكَ يُبَيِّنُ ٱللَّهُ لَكُمُ ٱلْـَٔايَـٰتِ لَعَلَّكُمْ تَتَفَكَّرُونَ ﴿٢١٩﴾

*219. ពួកគេសួរអ្នករឿងគ្រឿងស្រវឹង (គឺស្រា...) និងល្បែងស៊ីសង ។ ចូរអ្នកថ្លែង[ប្រាប់ពួកគេ]ថា៖ "ទាំងពីរនេះមានបាបធំ ហើយមានប្រយោជន៍ខ្លះសម្រាប់បណ្ដាមនុស្ស តែបាបរបស់វាទាំងពីរនេះធំជាងផលប្រយោជន៍របស់វាទាំងពីរ ។" ពួកគេសួរអ្នកអំពីអ្វីដែលពួកគេត្រូវចាយវាយ ។ ចូរអ្នកប្រាប់ថា៖ "អ្វីដែលលើស[ពីត្រូវការ]" ។ បែបនេះឯងដែលអល់ឡោះប្រ៏អធិប្បាយបំភ្លឺអំពីបណ្ដាសញ្ញា [និងបណ្ដាឱង្ការ] ដល់ពួកអ្នកដើម្បីពួកអ្នកនឹងត្រិះរិះ ។*

ល្បែងស៊ីសងជាប្រការ**ហារ៉ាំ** ព្រោះបុគ្គលអាចបាត់បង់ទ្រព្យអស់ពីខ្លួនទាំងមិនដឹងខ្លួន មិនត្រឹមតែសម្រាប់ខ្លួនឯងទេ តែសម្រាប់អស់បុគ្គលដែលនៅក្នុងបន្ទុក

ខ្លួនដែរ (ប្រពន្ធ កូន) ដែលខ្លួនខិតខំប្រកបកិច្ចការចិញ្ចឹមនោះ ។ ល្បែងស៊ីសងធ្វើឲ្យញៀន (អ្នកមិនអាចឈប់បានទេ កាលណាអ្នកចាប់ផ្ដើមលេងវាហើយ) ។

កាលណាអ្នកញៀនអ្វីមួយ បានសេចក្ដីថាអ្នកពិបាកដកខ្លួនចេញ ឬមិនអាចដកខ្លួនចេញបានតែម្ដង ។ ចូរកុំបណ្ដោយឲ្យអ្វីមួយធ្វើឲ្យអ្នកញៀនជាដាច់ខាត ព្រោះវានឹងគ្រប់គ្រងអ្នក ។ អ៊ីស្លាមចង់ឲ្យចិត្តអ្នកតែមួយគត់គ្រប់គ្រងខ្លួនអ្នក ។

កាលណាបុគ្គលលេងល្បែងស៊ីសង កាលនោះបុគ្គលនោះត្រូវល្បែងទាក់ទាញចិត្ត វាធ្វើឲ្យភ្លេចអ្វីៗទាំងអស់ ភ្លេចទាំងព្រះអ្នកបង្កើតខ្លួន ដល់ថ្នាក់វាអាចបំផ្លិចបំផ្លាញជីវិតបុគ្គលនោះបាន ។

**មេរៀនទី ១៨**

# បរិភោគជ្រូកឬរបស់ត្រូវហាម

យើងទាំងអស់គ្នាដឹងហើយថាគេហាមយើងបរិភោគជ្រូក និងសាច់សត្វណាដែលមិនត្រូវសំឡេះតាមច្បាប់អ៊ីស្លាម ។

អ្វីៗដែលអល់ឡោះហ៍ﷻថែងថាហាហ្រាំសម្រាប់យើង វាហ្រាំដោយមានមូលហេតុច្បាស់លាស់ គឺវាធ្វើឲ្យសុខភាពយើងខូច ។

គេសាកសួរខ្លួនឯងឬគ្នីគ្នាជាញឹកញយថា ហេតុអ្វីគេហាមបរិភោគសាច់ជ្រូក តែមិនហាមបរិភោគសាច់គោទេ ។ កាលពីមុននេះបន្តិចយើងមិនដឹងមូលហេតុទេ ។ វិទ្យាសាស្ត្របានស្រាវជ្រាវរកឃើញថាមានតែសាច់ជ្រូកទេដែលសប្បុរមេរោគជាងសាច់សម្រាប់បរិភោគទាំងអស់ ។ ពីព្រោះសត្វជ្រូកស៊ីសំរាម វាស៊ីកាកសំណល់ដូចជាផ្លែឈើស្អុយរលួយឬសំបកដំឡូងបារាំងជាដើម ដែលផ្ទុកនូវដង្កូវនិងសត្វល្អិតចម្លងជម្ងឺ ។ ពេលសត្វជ្រូកលេបចំណីទៅក្នុងពោះ ពួកដង្កូវនិងសត្វល្អិតចម្លងរោគចូលទៅក្នុងខ្លួនវា ហើយនៅតែរស់នៅក្នុងសាច់ជ្រូកនោះ ។ ពេលគេយកសាច់ជ្រូកនោះទៅលក់ គេមិនបានចម្អិនសាច់ជ្រូកនោះទេ ហេតុដូច្នេះសត្វដង្កូវល្អិតៗទាំងនោះនៅរស់ ។ បើសាច់ជ្រូកនោះមិនត្រូវចម្អិនឲ្យឆ្អិនល្អទេ ដង្កូវទាំងនោះចូលទៅក្នុងខ្លួនមនុស្ស ។ ហេតុដូច្នេះឯងបានជាអល់ឡោះហ៍ﷻហាមមនុស្សបរិភោគសាច់សត្វណាដែលស៊ីសំរាម ។

អ៊ីស្លាមហាមយើងបរិភោគសាច់ច្រើនប្រភេទទៀតដែរ ។ យើងដឹងថាយើងអាចបរិភោគសាច់គោបាន ។ គេអនុញ្ញាតឲ្យយើងបរិភោគសាច់គោ តែបើសាច់គោនោះមិនហាឡាល់ទេ យើងមិនអាចបរិភោគសាច់គោនោះបានទេ ព្រោះដើម្បីទៅជាហាឡាល់ ត្រូវតែសំឡេះសត្វគោតាមច្បាប់អ៊ីស្លាម ។

ប្រការសំខាន់ដែលត្រូវចងចាំក្នុងមេរៀននេះគឺ អ្វីៗដែលអល់ឡោះហ៍ﷻហាម ត្រូវហាមដើម្បីផលប្រយោជន៍យើង ។ ព្រះអង្គﷻមិនចង់ឲ្យយើងខូចសុខភាពទេ ឬមិនចង់ឲ្យយើងធ្វើប្រការណាមួយ ដែលអាចនឹងធ្វើឲ្យយើងរងគ្រោះថ្នាក់នៅពេល

អនាគតទេ ។

ទង្វើមួយចំនួនដែលសាសនាអ៊ីស្លាមហាមយើង អ្នកវិទ្យាសាស្ត្រមិនទាន់បានពិពណ៌នាអធិប្បាយមូលហេតុនៅឡើយទេ តែមិនបានសេចក្ដីថាយើងត្រូវធ្វើទង្វើនោះទេ (ឧទាហរណ៍ ស្តាប់តន្ត្រី) ។ យើងត្រូវសាកស្រាវជ្រាវរកមូលហេតុដែលវាហាមឃាត់ តែបើយើងរកមូលហេតុមិនឃើញទេ យើងត្រូវជឿជាក់ថាព្រោះតែគេចង់ឲ្យយើងល្អ ។

**មេរៀនទី ១៩**

# និយាយអាក្រក់អំពីគេ

និយាយអាក្រក់អំពីគេ បានសេចក្តីថានិយាយអំពីបុគ្គលណាម្នាក់ និយាយរឿងផ្ទាល់ខ្លួនរបស់អ្នកនោះ ជាពិសេសពេលអ្នកនោះអវត្តមាន (ពីក្រោយខ្នងគេ) នាំឲ្យគេទាស់ចិត្ត ។

មានពាក្យពីរសម្រាប់ហៅការនិយាយអាក្រក់អំពីគេ មួយគឺ គ៊ីបាស់ (غِيبَة) មួយទៀតគឺ ទុស្វម៉ាស់ (تُهْمَة) ។

ពេលអ្នកនិយាយអំពីបុគ្គលណាម្នាក់ ដោយនិយាយការពិត គេហៅថា គ៊ីបាស់ ។

ពេលអ្នកនិយាយអំពីបុគ្គលណាម្នាក់ ដោយនិយាយការមិនពិត គេហៅថា ទុស្វម៉ាស់ ។

គ៊ីបាស់ និង ទុស្វម៉ាស់ ជាប្រការហ្ញារ៉ាំពីរ (ត្រូវហាម) ។

ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "អាប៊ូ ស្ទារ អឺយ ចូរចៀសឆ្ងាយពីការនិយាយអាក្រក់អំពីគេ ព្រោះវាអាក្រក់លើសអំពើផិតក្បត់ ។ បន្ទាប់ពីបានប្រព្រឹត្តអំពើផិតក្បត់បើលោកស្តាយក្រោយលែងធ្វើទៀត អល់ឡោះហ៊្វ៏عزوجلលើកលែងទោសឲ្យលោក តែអ្នកនិយាយបង្ខូចគេមិនត្រូវលើកលែងទោសឲ្យទេដរាបណាបុគ្គលដែលត្រូវគាត់និយាយបង្ខូចនោះមិនលើកលែងទោសឲ្យគាត់ទេនោះ ។"

ពេលអ្នកបានឮគេជេរ អ្នកនិយាយប្រាប់មិត្តអ្នកឲ្យដឹងរឿងនេះពេលអ្នកជេរនោះមិននៅ (គឺនិយាយមិនឲ្យគាត់ដឹង) គេហៅថា គ៊ីបាស់ ។

នៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៏ 49 (អាល់-ហ៊្វូឃ្ញូរ៉ត) អាយ៉ាស់ 12 អល់ឡោះហ៊្វ៏عزوجلមានព្រះបន្ទូលថា៖

يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ ٱجۡتَنِبُواْ كَثِيرٗا مِّنَ ٱلظَّنِّ إِنَّ بَعۡضَ ٱلظَّنِّ إِثۡمٞۖ وَ لَا تَجَسَّسُواْ وَلَا يَغۡتَب بَّعۡضُكُم بَعۡضًاۚ أَيُحِبُّ أَحَدُكُمۡ أَن يَأۡكُلَ لَحۡمَ أَخِيهِ مَيۡتٗا فَكَرِهۡتُمُوهُۚ وَٱتَّقُواْ ٱللَّهَۚ إِنَّ ٱللَّهَ تَوَّابٞ رَّحِيمٞ ١٢

*12. បណ្ដាអ្នកមានសទ្ធាអើយ ចូរពួកអ្នកចៀសវាងប៉ាន់ស្មាន ព្រោះការពិត ក្នុងករណីខ្លះ ប៉ាន់ស្មានជាបាប ។ ចូរពួកអ្នកកុំលបយកការណ៍ ។ ចូរពួកអ្នកកុំនិយាយបង្កាច់អ្នកឯទៀត ។ តើមានអ្នកណាម្នាក់ក្នុងចំណោមពួកអ្នកចូលចិត្តស៊ីសាច់បងប្អូនឯងដែលស្លាប់នោះទេ ? ពួកអ្នកពិតជាស្អប់ខ្ពើមអំពើនេះខ្លាំងណាស់ ។ ចូរពួកអ្នកខ្លាចអល់ឡោះហ៍ ។ ពិតមែន អល់ឡោះហ៍រមែងតែបែរត្រឡប់ (ប្រោសប្រណីគឺទទួលការសូមខមាទោស) ព្រះអង្គមានព្រះធម៌មេត្តា ។*

សឲ្យឃើញថា និយាយបង្កាច់គេអាក្រក់ដូចស៊ីសាច់បងប្អូនខ្លួនឯងដែលបានស្លាប់ទៅហើយដែរ ។ បានសេចក្ដីថាពេលអ្នកបានដឹងថាបងប្អូនរួមសាសនាអ៊ីស្លាមប្រុស/ស្រីរបស់អ្នកបានធ្វើប្រការអាក្រក់ណាមួយ គាត់ ប្រុស/ស្រីនោះបានធ្វើឲ្យខូចកេរ្តិ៍ឈ្មោះខ្លួនឯងរួចស្រាប់ហើយ ។ ពេលអ្នកនិយាយប្រាប់គេទៀតអ្នកទាញយកផលប្រយោជន៍ពីចំណុចខ្សោយរបស់គាត់ ។ ហាក់ដូចជាអ្នកស៊ីផឹកយ៉ាងសប្បាយលើកេរ្តិ៍ឈ្មោះដែលគេ ប្រុស/ស្រីនោះ បានធ្វើឲ្យខូចហើយនោះ ។

សម័យអ៊ីម៉ាំមុនៗរបស់យើង عليهم السلام មានបុរសពីរនាក់ យើងហៅឈ្មោះគាត់ម្នាក់ថា ហ្វារូន ម្នាក់ទៀតឈ្មោះ ខ៏ុលីដ្វ ។

ថ្ងៃមួយ ខ៏ុលីដ្វបាននិយាយអាក្រក់អំពីហ្វារូនប្រាប់គេអស់ ។ គាត់និយាយមុសាជុំវិញខ្លួនគាត់ ។ ច្រើនថ្ងៃក្រោយមក ហ្វារូនដឹងរឿងនេះ ។ ពេលគាត់ទៅដល់ផ្ទះ គាត់បានយកប្រាក់និងមាសគាត់ទាំងអស់ដាក់ក្នុងថង់ធំមួយហើយយកទៅផ្ទះ ខ៏ុលីដ្វ ។

ពេលឃើញហ្វារូនមកដល់ គាត់ភ័យរន្ធត់ព្រោះគាត់គិតថាហ្វារូនប្រុងមកវាយគាត់ ។ ខ៏ុលីដ្វចេញពីក្នុងផ្ទះ លុតជង្គង់អង្វរហ្វារូនថាៈ "ហ្វារូនអើយ ខ្ញុំសោកស្ដាយណាស់ ខ្ញុំមិនមានចេតនានិយាយមុសាអំពីលោកទេ ។ ខ្ញុំសូមអង្វរ កុំវាយខ្ញុំអី !"

ហ្វារូនបានថាៈ "ខ្ញុំមិនមកវាយលោកទេ ។ ខ្ញុំមកនេះដើម្បីយកប្រាក់នេះមកឲ្យលោក ។"

ខ៍្លីដ្វតក់ស្លុតស្ទើរស្លាប់ ។

ហ្វារូននិយាយបន្តទៀតថា៖ "ខ៍្លីដ្វអឺយ ខ្ញុំមកដើម្បីសូមអរគុណលោក សូមលោកទទួលយកទ្រព្យទាំងអស់របស់ខ្ញុំទៅ ។"

ខ៍្លីដ្វងើបឡើង សួរថា៖ "ហេតុអ្វីលោកឲ្យទ្រព្យទាំងអស់របស់លោកមកខ្ញុំ ខ្ញុំបានប្រមាថលោក បានបង្ខូចឈ្មោះលោកប្រាប់គេទាំងអស់គ្នា ?"

ហ្វារូនតបថា៖ "ព្រះសាស្តាﷺមានព្រះវចនៈថាអ្នកណានិយាយអាក្រក់ពីគេពីក្រោយខ្នង រង្វាន់របស់អ្នកនិយាយបង្កាច់គេនោះត្រូវផ្ទេរឲ្យទៅអ្នកដែលត្រូវគេនិយាយបង្ខូច ។" ហ្វារូននិយាយបន្តទៀតថា៖ "ដូច្នេះ ពេលនេះ ដែលលោកបាននិយាយអាក្រក់អំពីខ្ញុំពីក្រោយខ្នងខ្ញុំ ខ្ញុំសូមអរគុណលោកដែលបានឲ្យរង្វាន់ទាំងអស់របស់លោកមកខ្ញុំ ។ ទ្រព្យទាំងនេះតិចណាស់ប្រៀបធៀបនឹងរង្វាន់ទាំងអស់ដែលលោកបានឲ្យមកខ្ញុំនោះ ។"

សឲ្យឃើញ "គ៏ីបាស្ទ" និង "ទុស្ខម៉ាស្ទ" ជាប្រការអាក្រក់ប៉ុណ្ណាខ្លះ ។

ថ្ងៃមួយ បុរសម្នាក់និយាយទុស្ខម៉ាស្ទដាក់អ៊ីម៉ាំទី ៦ របស់យើង صلوات الله عليه والسلام ។ អ៊ីម៉ាំ صلوات الله عليه والسلام មិនដឹងខ្លួនទេ ច្រើនថ្ងៃក្រោយមក "មិត្ត" ព្រះអង្គ صلوات الله عليه والسلام ម្នាក់បានមករកព្រះអង្គ صلوات الله عليه والسلام ទូលព្រះអង្គ صلوات الله عليه والسلام ថា៖ "អ៊ីម៉ាំ صلوات الله عليه والسلام អឺយ ទូលបង្គំបានទទួលដំណឹងគួរឲ្យខ្លាច ។ បុគ្គលនេះបាននិយាយអាក្រក់អំពីព្រះអង្គ صلوات الله عليه والسلام ។" អ៊ីម៉ាំ صلوات الله عليه والسلام ក្រោធ "មិត្ត" ព្រះអង្គ صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "ចូរគិតដល់អ្នកដែលនិយាយបង្កាច់ខ្ញុំ صلوات الله عليه والسلام ដូចជាអ្នកនោះបាញ់ព្រួញមកលើខ្លួនខ្ញុំ صلوات الله عليه والسلام ។ ព្រោះតែខ្ញុំ صلوات الله عليه والسلام មិនបានឮ វាដូចជាផ្លែព្រួញនោះបាញ់ខុសខ្ញុំ صلوات الله عليه والسلام ។ តែពេលលោកនាំដំណឹងនេះមកប្រាប់ខ្ញុំ صلوات الله عليه والسلام វាដូចជាលោករើសយកផ្លែព្រួញនោះពីដីមកចាក់លើខ្លួនខ្ញុំ صلوات الله عليه والسلام ។"

មុស្លីមល្អមានករណីយកិច្ចហាមគេមិនឲ្យនិយាយអាក្រក់អំពីអ្នកណាម្នាក់ បើមិនអាចធ្វើបានទេ ត្រូវចៀសចេញពីបណ្តាអ្នកដែលនិយាយអាក្រក់អំពីគេ ។

ហេតុអ្វី "គ៏ីបាស្ទ" និង "ទុស្ខម៉ាស្ទ" ជាប្រការហាមឃាត់ ?

វាជាប្រការហាមឃាត់ព្រោះវាបង្ខូចឈ្មោះនិងចរិតរបស់មនុស្ស ។ បើអ្នកនិយាយ

អាក្រក់អំពីអ្នកណាម្នាក់ អ្នកធ្វើឲ្យអ្នកដទៃគិតថាអ្នកនោះអាក្រក់ ។

មូលហេតុមួយទៀតដែលថាវាជាប្រការអាក្រក់នោះគឺ បណ្តាអ្នកដែលត្រូវគេនិយាយបង្ខូចនោះអវត្តមានដើម្បីនឹងអាចនិយាយតវ៉ាការពារខ្លួនបាន ។ បើអ្នកបានឮគេនិយាយអាក្រក់អំពីអ្នកដទៃ អ្នកត្រូវបើកផ្លូវឲ្យគេដើម្បីនឹងឲ្យគេអាចអធិប្បាយទង្វើរបស់ខ្លួនបាន មុននឹងជឿអ្វីដែលអ្នកបានឮនោះ ។

**មេរៀនទី ២០**

# ពាក់ចិញ្ចៀនមាសនិងគ្រឿងលំអសម្រាប់បុរស

គ្រឿងលំអគឺអ្វីៗដែលអ្នកពាក់ ។ អាចជាចិញ្ចៀន កងដៃឬខ្សែក ។ល ។

ពាក់មាសជាប្រការ**ហ៊ារ៉ាំ**សម្រាប់បុរស ទោះបីវាលាយជាមួយលោហធាតុពុំមានតម្លៃផ្សេងៗក៏ដោយ ។

តែគេអនុញ្ញាតមានធ្មេញ ឬវត្ថុសម្រាប់ញាត់បំពេញប្រហោងធ្មេញធ្វើអំពីមាស ។

**សំគាល់** - មាសត្រូវហាមចំពោះតែបុរសទេ ។ គេអនុញ្ញាតឲ្យស្ត្រីពាក់គ្រឿងលំអនិងសំលៀកបំពាក់ធ្វើអំពីមាសបាន ។

មូលហេតុមួយដែលអ៊ីស្លាមហាមបុរសពាក់មាសនោះគឺ មាសច្រើនតែជាគ្រឿងអលង្ការសម្រាប់ស្ត្រី ។ អ៊ីស្លាមមិនយល់ព្រមឲ្យបុរសសំអិតសំអាងខ្លួនដោយមាសឬសូត្រទេ ។

ដូច្នេះឯងបានអ៊ីស្លាមមិនអនុលោមទេ ដែលបុរសចំពាក់ចិត្តទៅលើប្រណិតភាពនិងភាពសម្បូរហូរហៀរនោះ ។ បុរសត្រូវរឹងមាំ ត្រូវប្រកបកិច្ចការដើម្បីចិញ្ចឹមជីវិតខ្លួនឯងនិងគ្រួសារ ។ បើខ្លួនជាអ្នកមាន បុរសមិនចាំបាច់បង្ហាញទ្រព្យខ្លួនអាស្រ័យប្រណិតភាពទេ ។

មូលហេតុដែលគេអនុញ្ញាតឲ្យមានធ្មេញធ្វើអំពីមាស ឬគ្រឿងសម្រាប់ញាត់ប្រហោងធ្មេញធ្វើអំពីមាសនោះ ព្រោះមាសជាលោហធាតុមានតម្លៃដែលមានប្រតិកម្មតិចបំផុត ។ បានសេចក្តីថាពេលអ្នកបរិភោគ អ្វីក៏ដោយដែលអ្នកបរិភោគធ្មេញធ្វើពីមាសឬគ្រឿងសម្រាប់ញាត់ប្រហោងធ្មេញធ្វើអំពីមាសនោះអសកម្ម វាមិនមានប្រតិកម្មទេពេលប៉ះនឹងចំណី ។

## មេរៀនទី ២១ ដេកផ្កាប់មុខ

# ដេកផ្កាប់មុខ

អ៊ីស្លាមមិនអនុលោម (ម៉ាក់រ៉ុះហ៍ مَكْرُوهٌ) ឲ្យដេកផ្កាប់មុខទេ ។

មូលហេតុដែលអ៊ីស្លាមមិនអនុលោមឲ្យដេកផ្កាប់មុខនោះគឺ វាប៉ះពាល់ដល់សុខភាព ។

ដេកផ្កាប់មុខវាសង្កត់បេះដូងនិងទ្រូងអ្នក ។ នេះមកពីទម្ងន់ខ្លួនអ្នកធ្ងន់ពេកសម្រាប់ទ្រូងអ្នក ព្រោះទ្រូងអ្នកត្រូវកម្រើកបានដោយស្រួលពេលអ្នកដកដង្ហើមចេញចូល ។ គេអាចអធិប្បាយបានថាទម្ងន់ខ្លួនអ្នកសង្កត់លើសួត ព្រោះសួតមិនអាចទ្រទម្ងន់សង្កត់ធ្ងន់បែបនេះបានទេ ។

ក្រោយពីបានបរិភោគរួច ដេកផ្កាប់មុខអាចប៉ះពាល់ដល់ការរំលាយអាហារនិងការដកដង្ហើមចេញចូលបាន ។ ដូច្នេះ ក្រោយពីបានបរិភោគច្រើនអ្នកគប្បីដេកផ្អៀងខ្លួនទៅខាងស្តាំ ។

អ៊ីស្លាមបានបង្ហាត់បង្រៀនយើង ឲ្យចេះដឹងរឿងនេះច្រើនសតវត្សរ៍មុនមកម្ល៉េះ វិទ្យាសាស្ត្រពេទ្យទើបតែបានបញ្ជាក់ប្រាប់យើងឲ្យដឹងរឿងនេះបច្ចុប្បន្ននេះទេ ។

*sources:*
www.saba-igc.org
shia974.fr
www.madressa.net

អ៊ីម៉ាំមេម៉ាស្ហាប់ទាំង ៤ ។

| ឈ្មោះអ៊ីម៉ាំមេម៉ាស្ហាប់ | ម៉ាស្ហាប់ | ថ្ងៃកំណើត/ថ្ងៃស្លាប់ សកករាជហ៊ិជ្រ៉ោះត្ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ្រិស្តសករាជ |
|---|---|---|---|
| អាប៊ូ ហ្លានីហ្វាស្ | ហាណាហ្វី | 80-150 ស.ហ. | 699-767 គ.ស. |
| ម៉ាលិក | ម៉ាលីគី | 93-179 ស.ហ | 711-795 គ.ស. |
| អាស្-ស្ហាហ្វីអ៊ី | ស្ហាហ្វីអ៊ី | 150-204 ស.ហ | 767-820 គ.ស. |
| អាស្ម៉ាដ្ ហ្លាន់បាល់ | ហ្លាន់បាលី | 164-241 ស.ហ. | 780-855 គ.ស. |

ព្រះសាសា មូហ្ហាំម៉ាដ្ ប្រសូត/ចូលព្រះទិវង្គត ឆ្នាំ 570-632 គ.ស.

អ៊ីម៉ាំអ្នកស្នងព្រះសាស្តាមូហ្ហាំម៉ាដ្ﷺទាំង ១២ ។

| លំដាប់ | ឈ្មោះ | ឈ្មោះក្រៅ | ឋាននន្តរស័ក្តិ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ.ស./ស.ហ. |
|---|---|---|---|---|
| 1 | អ៊ុលី | អាប៊ូ អាល់-ហ្ហាសាន់ | អាមីរុល-មុមីនីន | 600-661/23 មុន ស.ហ.-40 |
| 2 | ហ្ហាសាន់ | អាប៊ូ មូហ្ហាំម៉ាដ្ | អាល់-មុច្ចតាបា | 625-670/3-50 |
| 3 | ហ្ហូសែន៍ | អាប៊ូ អ៊ុប់ឌុលឡោះហ្ | សៃយីដុ អាស្-ស្ហុហាដាអ៍ | 626-680/4-61 |
| 4 | អ៊ុលី ប៊ិន ហ្ហូសែន៍ | អាប៊ូ មូហ្ហាំម៉ាដ្ | អាស់-សាច្ចយ៉ាដ្ ស្សៃនុល-អាប៊ីឌីន | 659-713/38-95 |
| 5 | មូហ្ហាំម៉ាដ្ អាល់-បាក្វៀរ | អាប៊ូ យ៉ាក់ហ្វារ | បាក្វៀរ អាល់-អ៊ុលូម | 676-733/57-114 |
| 6 | យ៉ាក់ហ្វារ | អាប៊ូ អ៊ុប់ឌុលឡោះហ្ | អាស្-ស្វ៍ឌិក្វ | 702-765/83-148 |
| 7 | មូសា ប៊ិន យ៉ាក់ហ្វារ | អាប៊ូ អាល់-ហ្ហាសាន់ | អាល់-កាស្ទីម | 745-799/128-183 |
| 8 | អ៊ុលី ប៊ិន មូសា | អាប៊ូ អាល់-ហ្ហាសាន់ | អារ-រីដ្ហា | 765-819/148-203 |
| 9 | មូហ្ហាំម៉ាដ្ ប៊ិន អ៊ុលី | អាប៊ូ យ៉ាក់ហ្វារ | អាត់-តាគ្គី អាល់-យ៉ាវ៉ាដ្ | 811-835/195-220 |
| 10 | អ៊ុលី ប៊ិន មូហ្ហាំម៉ាដ្ | អាប៊ូ អាល់-ហ្ហាសាន់ | អាល់-ហ្ហាឌី អាន់-ណាគ្គី | 828-868/212-254 |
| 11 | ហ្ហាសាន់ ប៊ិន អ៊ុលី | អាប៊ូ មូហ្ហាំម៉ាដ្ | អាល់-អ៊ុស់ការី | 846-874/232-260 |
| 12 | មូហ្ហាំម៉ាដ្ ប៊ិន ហ្ហាសាន់ | អាប៊ូ ក្វ៍ស៊ីម | អាល់-ម៉ាស្ឌី អាល់-ហ្ហុច្ចយ៉ាស្ ស្វ៍ហ្ហីប អាល់-ស្សាម៉ាន អាល់-ក្វ៍អ៊ីម | 869/255 |